ក

មាតិកា

I~ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៦-៤-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៥០៧/២០០ ស្ដីពីការតែងតាំងឯកឧត្តម **ហុង បញ្ញារិទ្ធ** ជាអគ្គាធិការ នៃអគ្គាធិការដ្ឋាន ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ៣៩៦៤

២៤-៥-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៥០៧/២០១ ស្ដីពីការតម្លើងថ្នាក់ក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ចំនួន ០៥ រូប និង នៅទីស្ដីការគណៈរដ្ឋមន្ត្រី តាមកំរិតសញ្ញាប័ត្រ ចំនួន ០២ រូប ៣៩៦៥

២៤-៥-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៥០៧/២០២ ស្ដីពីការប្រោសព្រះរាជទាន ចំពោះ លោកជំទាវឧកញ៉ា **ស៊ុយ សុផាន** នូវ គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ៣៩៦៧

២៤-៥-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៥០៧/២០៣ ស្ដីពីការប្រោសព្រះរាជទានប្រគេនចំពោះព្រះឃោសធម្ម **ញ៉ែម សុគំរូ** នូវ គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ៣៩៦៨

២៤-៥-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៥០៧/២០៤ ស្ដីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ ធិបឌិន្ទ ចំពោះ លោក **សែម គីថាយ** ៣៩៦៩

២៦-៥-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៥០៧/២០៧ ស្ដីពីការតែងតាំងឯកឧត្តម ចំនួន ០៤ រូប មានឋានៈស្មើ រដ្ឋមន្ត្រី និងស្មើ រដ្ឋលេខាធិការ ៣៩៧០

២៦-៥-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៥០៧/២០៨ ស្ដីពីការតម្លើងឋានៈ ជូនឯកឧត្តម លោកជំទាវ និងពិធីការ សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចំនួន ០៦ រូប ៣៩៧១

២៦-៥-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៥០៧/២០៩ ស្ដីពីការតែងតាំងឯកឧត្តម **ម៉ុន ហុង** ជាអនុរដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ ជំនួសឯកឧត្តម **អ៊ិន នាង** ដែលបានទទួលមរណភាព ៣៩៧៣

២៦-៥-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៥០៧/២១១ស្ដីពីការតែងតាំងឯកឧត្តម **ព្រហ្ម ញាណវិចិត្រ** ជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សំរាប់អាណត្តិថ្មី ៣៩៧៤

II-រាជរដ្ឋាភិបាល

អនុក្រឹត្យ

២៨-៥-២០០៧	-អនុក្រឹត្យលេខ ៥១ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា	៣៩៧៥
២៩-៥-២០០៧	-អនុក្រឹត្យលេខ ៥២ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា	៣៩៧៧
២៩-៥-២០០៧	-អនុក្រឹត្យលេខ ៥៣ អនក្រ.បក ស្តីពីការកំណត់ប្រាក់ឧបត្ថម្ភសម្រាប់ មន្ត្រីរាជការស៊ីវិល ដែលបានបញ្ចប់ការបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល	៣៩៧៩
៣០-៥-២០០៧	-អនុក្រឹត្យលេខ ៥៤ អនក្រ.បក ស្តីពីការប្រើប្រាស់គណនីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ	៣៩៨២
២៨-៥-២០០៧	-អនុក្រឹត្យលេខ ៤១៣ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិ នាយទាហាន	៣៩៨៤
២៨-៥-២០០៧	-អនុក្រឹត្យលេខ ៤១៤ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ	៣៩៨៦
២៨-៥-២០០៧	-អនុក្រឹត្យលេខ ៤១៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	៣៩៨៨
២៨-៥-២០០៧	-អនុក្រឹត្យលេខ ៤១៦ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ	៣៩៨៩
២៩-៥-២០០៧	-អនុក្រឹត្យលេខ ៤១៧ អនក្រ.តត ស្តីពីការអនុញ្ញាតអោយមន្ត្រីរាជការស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស	៣៩៩១
២៩-៥-២០០៧	-អនុក្រឹត្យលេខ ៤១៨ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ	៣៩៩២

III-ការិយាល័យបណ្តាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

២២-៥-២០០៧	-ប្រកាសលេខ ៧០ ប្រក/រប ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់	៣៩៩៤

២-ទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

១៨-៥-២០០៧	-សេចក្តីណែនាំលេខ ០០៨ សណន ស្តីពីការចុះសៀវភៅអត្រានុកូលដ្ឋានឱ្យមាននិរន្តរភាពក្រោយ បញ្ចប់យុទ្ធនាការចុះសៀវភៅអត្រានុកូលដ្ឋានចល័ត	៤០០២

៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២៥-០១-២០០៧	-លិខិតបញ្ជាក់លេខ ០៤១៩ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ភ្នែក**	៤០១៦

២៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤២០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខសម៉ូស ខេ & ស៊ី ភីធីអ៊ី អិលធីឌី** ៤០១៨

២៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤២២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ដេវខូ យែតថល (ខេមបូឌា)** ៤០២០

២៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤២៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉េង ជា** ៤០២២

២៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤២៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិមអេសស៊ី អ៊ិនវេសមេន អ៊ែតវ៉ាយហ្ស៊ែរ (ខេមបូឌា)** ៤០២៤

២៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤២៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ចាងទ៊ុន** ៤០២៦

២៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤២៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេល ស្កុតឡូត (ខេមបូឌា)** ៤០២៨

២៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤៣០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស ធី លី អេខ អ៊ីមផត អិចផត** ៤០៣០

២៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤៣១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យែតថល ឌីស្ទ្រីប៊្យូទ័រ ភីធីអ៊ី អិលធីឌី** ៤០៣២

២៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤៣៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មណ្ឌលរតនៈ** ៤០៣៤

២៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤៣៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សាន & អាសូស៊ីអេត** ៤០៣៦

២៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤៣៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វាន់_ផ្លេនិត** ៤០៣៨

ឃ

២៦-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤៣៧ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន**ខេ.អិល.គី ខូ អិលធី ឌី** ៤០៤០

២៦-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤៣៨ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មេគង្គ ទើលដ៍ ត្រាវែល & ធួរ** ៤០៤២

២៦-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤៤០ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិម ឌី អិល កសិកម្ម** ៤០៤៤

ព្រះរាជក្រឹត្យ

នស/រកត/០៥០៧/២០០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម **ហុង បញ្ញារិទ្ធ** ជាអគ្គាធិការ នៃអគ្គាធិការដ្ឋាន ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ជករ

នរោត្តម សីហមុនី

៣រល.០៧០៥.២១២

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ. ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៧

លេខ: ៤០៦ ច.ល
ចម្លងចែកជូន
ភ្នំពេញ ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៧
... ទីស្តីការគណៈរដ្ឋមន្ត្រី / រាជរដ្ឋាភិបាល

ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៥០៧/២០១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតម្លើងថ្នាក់មន្ត្រីរាជការឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច គិតចាប់ពី ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦ តទៅ មានដូចខាងក្រោម ÷

LE MINISTRE DU PALAIS ROYAL

2/3

១	ឯកឧត្តម ទឹម ជាសោភ័ណ្ឌ	ពីឧត្តមមន្ត្រី ថ្នាក់លេខ ២	ទៅថ្នាក់លេខ ១
២	ឯកឧត្តម ឌុច សុវណ្ណារី	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣	ទៅថ្នាក់លេខ ២
៣	ឯកឧត្តម គ្រួច ម៉ុនលី	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣	ទៅថ្នាក់លេខ ២
៤	ឯកឧត្តម សុខ គុន	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣
៥	ឯកឧត្តម នេង សារឿន	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥	ទៅថ្នាក់លេខ ៤

មាត្រា ២ : ត្រូវបានតម្លើងថ្នាក់មន្ត្រីរាជការឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្តីការ-គណៈរដ្ឋមន្ត្រី តាមកិតសញ្ញាប័ត្រ មានដូចខាងក្រោម ៖

១	ឯកឧត្តម ឡេង សុជា	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣	ទៅថ្នាក់លេខ ២
២	ឯកឧត្តម ហង្ស ធារិទាន	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤	ទៅថ្នាក់លេខ ៣

មាត្រា ៣ : មន្ត្រីដែលត្រូវបានតម្លើងថ្នាក់ដូចមានឈ្មោះក្នុងមាត្រា ២ ខាងលើ ត្រូវបានរក្សាទុកអតីតភាពសម្រាប់ឡើងថ្នាក់តាមវេនជ្រើសរើស និងវេនអតីតភាពដដែល ។

មាត្រា ៤ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៦ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៧៧.០៧០៥.២១៣

ធ្វើនៅព្រះបរមរាជវាំង.រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៧

លេខ: ២៦១១ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៧

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

នស/រកត/០៥០៧/២០៧

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

លោកជំទាវឧកញ៉ា ស៊ុយ សុផាន

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៤ល.០៧០៥.២១៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ. ថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០០៧

លេខៈ ២១៤ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៥០៧/២០៣

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ប្រគេនចំពោះ

ព្រះឃោសធម្ម ញៀម សុគន្ធ

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ចករ

នរោត្តម សីហមុនី

៣៧.០៧០៥.២១៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៧

លេខៈ ២១៣៦.ល
ដើម្បីចម្លងចែក
ថ្ងៃទី ខែ ឧសភា ឆ្នាំ២០០៧
ទីស្ដីការគណៈរដ្ឋមន្ត្រី

ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៥០៧/២០៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ ធិបឌិន្ទ

ចំពោះ

លោក សែម គីថាយ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣/ល.០៧០៥.២១៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ. ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៧

លេខ ៧១៤ ច.ល
ថតចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៥០៧/២០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១.- ត្រូវបានតែងតាំង ÷

១-ឯកឧត្តម នាំង សុខ ជាទីប្រឹក្សារាជរដ្ឋាភិបាល មានឋានៈស្មើ រដ្ឋមន្ត្រី

២-ឯកឧត្តម កែវ សាន ជាសមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានឋានៈស្មើ រដ្ឋលេខាធិការ

៣-ឯកឧត្តម ផៃ ស៊ីផាន ជាសមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានឋានៈស្មើ រដ្ឋលេខាធិការ

៤-ឯកឧត្តម នរៈរតនៈវឌ្ឍនោ ជាសមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានឋានៈស្មើ រដ្ឋលេខាធិការ។

មាត្រា២.- សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៧.០៧០៥.២១៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០០៧

លេខ ២១៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែឧសភា ឆ្នាំ២០០៧

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៥០៧/២០៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១៖ ត្រូវបានតម្លើងឋានៈ ជូនឯកឧត្តម លោកជំទាវ ជំនួយការ និងពិធីការ សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចំនួន ០៦ រូប ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម	ផាវ សាវី	ជំនួយការ	មានឋានៈស្មើ អនុរដ្ឋលេខាធិការ
២- ឯកឧត្តម	ប៊ុន ខេង	ជំនួយការ	មានឋានៈស្មើ អគ្គនាយក
៣- ឯកឧត្តម	សំ វណ្ណារ៉ា	ជំនួយការ	មានឋានៈស្មើ អគ្គនាយក
៤- ឯកឧត្តម	ឈន ប៉េងឡេង	ជំនួយការ	មានឋានៈស្មើ អគ្គនាយក
៥- ឯកឧត្តម	សុខ សូរិយា	ពិធីការ	មានឋានៈស្មើ អគ្គនាយក
៦- លោកជំទាវ	រស់ ច័ន្ទផល្លី	ពិធីការ	មានឋានៈស្មើ អគ្គនាយក ។

មាត្រា ២៖ ត្រូវបានតែងតាំង :

១- ឯកឧត្តម ងួន សំណាង ជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ អគ្គនាយក

២- ឯកឧត្តម ជា សារឿន ជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ អគ្គនាយក

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៣- ឯកឧត្តម កេត សោផាន់ ជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ៣ៈ សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ៈ ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣រល.០៧០៥.២២០

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៧

លេខៈ ២១៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ [illegible] ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] ជីនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៥០៧/២០៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១.- ត្រូវបានតែងតាំង ឯកឧត្តម **មុិន ហុន** ជា **អនុរដ្ឋលេខាធិការ** ក្រសួងយុត្តិធម៌ ជំនួសឯកឧត្តម **អុិន នាង** ដែលបានទទួលមរណភាព។

មាត្រា២.- សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៧.០៧០៥.២២១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៧

លេខ [illegible] ច.ល
ដើម្បីចម្លងចែក
ភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៥០៧/២១១

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស . រកត . ០៧០៤ . ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩ នស.៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស / រកម / ០៤៩៨ / ០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុម ប្រឹក្សានៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៧

ត្រាស់បង្គាប់

មាត្រា១ : តែងតាំង ឯកឧត្តម **ព្រហ្ម ញាណវិចិត្រ** ជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សំរាប់អាណត្តិថ្មី ។

មាត្រា២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣ : ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ន សីហមុនី

នរោត្តម សីហមុនី

៣៣ប.០៧០៥.២២៣

បានប្រថាប់ព្រះរាជលញ្ឆករហើយ

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៧

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ : ០០៥/០៧ រ.ចទ
រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៧
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រេិង្ការ
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

គង់ សំអុល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥១ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ,ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និងប្រកាសលេខ ១៤០១ សហវ.ប្រក.ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ , ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ១០.០០០ លានរៀល (ដប់ពាន់លានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦៥ (ឧបត្ថម្ភកធន និង ជំនួយសង្គម) ជូនទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចំណាយបំរើការងារចាំបាច់របស់រាជរដ្ឋាភិបាលឆ្នាំ ២០០៧ និងសំរាប់ទូទាត់ជំរះបុរេប្រទានថវិកាឆ្នាំ ២០០៦ ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥៦២ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ,ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និងប្រកាសលេខ ១៤០១ សហវ.ប្រក.ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ , ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៤០៩ លានរៀល (បួនរយប្រាំបួនលានរៀលគត់) ពីជំពូក ៦០ (ការទិញ) មកជំពូក ៦១ (សេវាខាងក្រៅ) ជូនក្រសួងការពារជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ទូទាត់សងថ្លៃការរៀបចំបណ្តាញអគ្គីសនី នៅក្នុងមន្ទីរពេទ្យព្រះកេតុមាលា ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកំណត់ប្រាក់បំណាច់ឧបត្ថម្ភសម្រាប់មន្ត្រីរាជការស៊ីវិល ដែលបានបញ្ចប់ការបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៤៩៥/៤០ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៥ ស្តីពី ការបង្កើតសាលាភូមិន្ទរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពី បៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០២ ស្តីពីការកែសម្រួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និងប្រាក់កំរៃគរុកោសល្យក្នុងវិស័យអប់រំ
- បានឃើញអនុក្រឹត្យលេខ ៩៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៥ ស្តីពី ការកែប្រែប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីលក្ខន្តិកៈរបស់សាលាភូមិន្ទរដ្ឋបាល

- យោងតាមស្មារតីនៃអង្គប្រជុំក្រុមប្រឹក្សាភិបាលរបស់សាលាភូមិន្ទរដ្ឋបាល កាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៦
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាភិបាលរបស់សាលាភូមិន្ទរដ្ឋបាល

សម្រេច

មាត្រា ១.-

អនុក្រឹត្យនេះ មានគោលដៅកំណត់ឱ្យបានសមស្របនូវប្រាក់បំណាច់ឧបត្ថម្ភប្រចាំខែ សម្រាប់មន្ត្រីរាជការស៊ីវិល ដែលបានបញ្ចប់ការបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល បន្ថែមលើប្រាក់បៀវត្សមូលដ្ឋាន ដោយគិតចាប់តាំងពីខែកក្កដា ឆ្នាំ ២០០៧ តទៅ ។

មាត្រា ២.-

ប្រាក់បំណាច់ឧបត្ថម្ភប្រចាំខែរបស់មន្ត្រីរាជការស៊ីវិល ដែលបានបញ្ចប់ការបណ្តុះបណ្តាលដំបូង នៅសាលាភូមិន្ទរដ្ឋបាល ហើយដែលកំពុងបម្រើការងារស៊ប់ក្នុងក្របខ័ណ្ឌរដ្ឋនៅតាមក្រសួង-ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ត្រូវបានកំណត់ដូចខាងក្រោម :

១. មន្ត្រីរាជការស៊ីវិលដែលបានបញ្ចប់ការបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល វគ្គសិស្សមន្ត្រីជាន់ខ្ពស់ ត្រូវបានទទួលប្រាក់បំណាច់ឧបត្ថម្ភប្រចាំខែ ស្មើនឹងប្រាក់បំណាច់មុខងារប្រចាំខែរបស់អនុប្រធាននាយកដ្ឋាន ។

២. មន្ត្រីរាជការស៊ីវិលដែលបានបញ្ចប់ការបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល វគ្គសិស្សមន្ត្រីក្រមការ ត្រូវបានទទួលប្រាក់បំណាច់ឧបត្ថម្ភប្រចាំខែ ស្មើនឹងប្រាក់បំណាច់មុខងារប្រចាំខែរបស់អនុប្រធានការិយាល័យថ្នាក់កណ្តាល ។

ប្រាក់បំណាច់ឧបត្ថម្ភប្រចាំខែរបស់មន្ត្រីរាជការស៊ីវិល ដែលបានបញ្ចប់ការបណ្តុះបណ្តាលដំបូង នៅសាលាភូមិន្ទរដ្ឋបាល ហើយដែលស្ថិតនៅក្នុងកម្មសិក្សាក្នុងក្របខ័ណ្ឌរដ្ឋនៅតាមក្រសួង-ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ត្រូវបានកំណត់ដូចខាងក្រោម :

១. មន្ត្រីរាជការស៊ីវិលដែលបានបញ្ចប់ការបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល វគ្គសិស្សមន្ត្រីជាន់ខ្ពស់ ត្រូវបានទទួលប្រាក់បំណាច់ឧបត្ថម្ភប្រចាំខែ ចំនួន ៣០០ ០០០ រៀល (**សាមសិបម៉ឺនរៀល**) ។

២. មន្ត្រីរាជការស៊ីវិលដែលបានបញ្ចប់ការបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល វគ្គសិស្សមន្ត្រីក្រមការ ត្រូវបានទទួលប្រាក់បំណាច់ឧបត្ថម្ភប្រចាំខែ ចំនួន ៦០ ០០០ រៀល (**ប្រាំមួយម៉ឺនរៀល**) ។

មាត្រា ៣.-

ប្រាក់បំណាច់ឧបត្ថម្ភប្រចាំខែ សម្រាប់មន្ត្រីរាជការស៊ីវិល ដែលបានបញ្ចប់ការបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល ដូចមានចែងក្នុងមាត្រា ២ ត្រូវបានជំនួសដោយប្រាក់បំណាច់មុខងារ នៅពេលដែលមន្ត្រីនោះ ទទួលបានការតែងតាំងក្នុងមុខតំណែង ដែលមានប្រាក់បំណាច់មុខងារខ្ពស់ជាងប្រាក់បំណាច់ឧបត្ថម្ភនេះ ។

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

សុខ អាន

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៤ . អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការប្រើប្រាស់គណនី

ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០២/០២១ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣
- បានឃើញប្រកាសរបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ១៩៩៤ ស្តីពីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៥ ស្តីពីបែបបទនៃឯកជនភាវូបនីយកម្មសហ

គ្រាសសាធារណៈ

- សេចក្តីសំរេចលេខ ០២ សសរ របស់រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០៤
- សេចក្តីជូនដំណឹងលេខ ៥៤៨ សជណ.សរ ចុះថ្ងៃទី ០៥ ខែ មេសាឆ្នាំ ២០០៥ ស្តីពីលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី ២៥ ខែ មិនា ឆ្នាំ ២០០៥
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

មាត្រា ១ .- អនុញ្ញាតអោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រើប្រាស់គណនី "ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ" ដែលត្រូវបានបង្កើតឡើងតាមមាត្រា ៨៣ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ លើមុខសញ្ញាចំណាយសំរាប់ការទូទាត់ជូនទូរគមនាគមន៍កម្ពុជា លើផលប៉ះពាល់ដល់បណ្តាញខ្សែកាប្លិ៍អុបទិកដោយសារគំរោងការស្តារឡើងវិញកំណាត់ផ្លូវជាតិលេខ ១ (ភ្នំពេញ-អ្នកលឿង) ដែលមានទឹកប្រាក់សរុបចំនួន *៣៧៩.៤០២,៦៥ដុល្លារអាមេរិក* បីរយចិតសិបប្រាំបួនពាន់បួនរយពីរដុល្លារអាមេរិកនិងហុកសិបប្រាំសេន) ។

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួង-ស្ថាប័នពាក់ព័ន្ធមានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៧

ហ៊ុន សែន

...បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ចំលងជូន:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ២
- ឯកសារ-កាលប្បវត្តិ ✓

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤១៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតម្លើងឋានន្តរស័ក្តិ នាយទាហាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជា អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

ស ម្រេ ច

មាត្រា១ : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ÷

១-វរសេនីយ៍ទោ **សោត សឿន** អត្តលេខ ០០៩៥២០ ប្រធាន ទទួលបន្ទុកជំនាញ ភស្តុភារហិរញ្ញវត្ថុ មជ្ឈមណ្ឌលបោសសំអាតមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងបណ្តុះបណ្តាល

២-វរសេនីយ៍ទោ **គន់ សារី** អត្តលេខ ០០៩៥៣០ ប្រធាន ទទួលបន្ទុកជំនាញ សំភារៈបច្ចេកទេស មជ្ឈមណ្ឌលបោសសំអាតមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងបណ្តុះបណ្តាល

៣-វរសេនីយ៍ទោ **អ៊ុន ពីទីម** អត្តលេខ ០១៤៥២៩ ប្រធាន ទទួលបន្ទុកជំនាញ ផែនការ ស្រាវជ្រាវ បោះផ្លាកសញ្ញា ទិន្នន័យ និងត្រួតពិនិត្យ មជ្ឈមណ្ឌលបោសសំអាតមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងបណ្តុះបណ្តាល

៤-វរសេនីយ៍ទោ **ទិន ឌី** អត្តលេខ ០០៩៥៩០ អនុប្រធាន ទទួលបន្ទុកជំនាញ ប្រតិបត្តិការ មជ្ឈមណ្ឌលបោសសំអាតមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងបណ្តុះបណ្តាល

៥-វរសេនីយ៍ទោ **ឃ្លោក សារី** អត្តលេខ ០០៣៤៥៣ អនុប្រធានទទួលបន្ទុកជំនាញ រដ្ឋបាល បុគ្គលិក អធិការកិច្ច ទំនាក់ទំនងសាធារណៈ និងឃោសនាពត៌មាន មជ្ឈមណ្ឌលបោសសំអាតមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងបណ្តុះបណ្តាល

៦-វរសេនីយ៍ទោ **ស៊ូ សុវណ្ណ** អត្តលេខ ០០៣៤៤០ អនុប្រធាន ទទួលបន្ទុកជំនាញ គុណភាពកោសល្យវិច្ច័យ មន្ទីរពិសោធន៍ និងបណ្ណាល័យ មជ្ឈមណ្ឌលបោសសំអាតមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងបណ្តុះបណ្តាល

៧-វរសេនីយ៍ទោ **ស សារី** អត្តលេខ ០០២១៤៦ នាយករង សាលាហ្វឹកហ្វឺន បោសសំអាតមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងបណ្តុះបណ្តាល មជ្ឈមណ្ឌលបោសសំអាតមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងបណ្តុះបណ្តាល

ប្រការ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងបណ្តាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤១៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតម្លើងឋានន្តរសក្តិ ជាកិច្ចបច្ឆាមរណៈ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យរបស់ ក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

ស ម្រេ ច

មាត្រា១ : ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជាកិច្ចបច្ឆាមរណៈ ជូនសព

១-វរសេនីយ៍ទោ **សេង សម្បត្តិ** អត្តលេខ ០១២០៥៥ មេបញ្ជាការរង កងរាជអាវុធហត្ថ ខេត្តតាកែវ

២-វរសេនីយ៍ទោ **សម ទ័យ** អត្តលេខ ០០៥១៩៧ មេបញ្ជាការរង កងរាជអាវុធហត្ថ ក្រុងប៉ៃលិន

៣-វរសេនីយ៍ទោ **ហ៊ុយ ពិសី** អត្តលេខ ០០៣៧៥០ មេបញ្ជាការរង កងរាជអាវុធហត្ថខេត្តកណ្តាល

មាត្រា២: រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្ត អនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤១៥.អនក្រ.បក

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០២/០១៥ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្ការ និងការប្រយុទ្ធ ទប់ស្កាត់ ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍
- បានឃើញអនុក្រឹត្យ លេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- យោងតាមសំណើរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងលោក ស៊ឹម គឹមសែន ជាអគ្គលេខាធិការរង នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាម៉ីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៦៧. អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភិរណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មាធិការរៀបចំស្តង់ដាអក្សរក្រមខ្មែរក្នុងកុំព្យូទ័រ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភិរណ្ឌ** តាមលំដាប់ថ្នាក់ ជូនឯកឧត្តម អស់លោក លោកស្រី ចំនួន ១២រូប ដែលមានស្នាដៃល្អ ក្នុងការងាររៀបចំស្តង់ដាអក្សរក្រមខ្មែរក្នុងកុំព្យូទ័រ ដូចមានរាយនាមខាងក្រោម :-

ក_មេដាយមុនីសារាភិរណ្ឌ ថ្នាក់ ធិបឌិន្ទ :

១-ឯកឧត្តម **ស៊ុំ ម៉ារិត**	ប្រធានគណៈកម្មាធិការ
២-ឯកឧត្តម **ឆាន់ សុវណ្ណសំរិទ្ធិ**	អនុប្រធាន

ខ_មេដាយមុនីសារាភិរណ្ឌ ថ្នាក់ សេនា :

១-ឯកឧត្តម **អ៊ឹង ឫទ្ធី**	សមាជិក
២-ឯកឧត្តម **ស្វាង លាងហៃ**	ទីប្រឹក្សា
៣-លោក **ជា សុខហ៊ួរ**	សមាជិក
៤-លោក **តុប ឫទ្ធី**	ទីប្រឹក្សា
៥-បណ្ឌិត **ឡេវ គីមលាង**	ទីប្រឹក្សា
៦-សាស្ត្រាចារ្យ **ហារ៉ាដា ស៊ីរ៉ូ** (Harada Shiro)	ទីប្រឹក្សា
៧-បណ្ឌិត **ស្វាយ ឡេង**	ទីប្រឹក្សា
៨-លោកស្រី **ម៉ារីយ៉ា អ៊ឹង** (Maria Ng)	ទីប្រឹក្សា

គ-មេជាយមុនីសារាគំណត្ត ថ្នាក់ អស្សរប្បន្ទិ :

១-លោកស្រី **ហេឡែន ចាវីស** (Helen Javis) ទីប្រឹក្សា

២-លោក **នូប៊ើត ក្លាញ** (Norbert Klein) ទីប្រឹក្សា

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មាធិការរៀបចំសួនជាអក្សរក្រមខ្មែរក្នុងកុំព្យូទ័រ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា ១ និង មាត្រា ២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤១៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការអនុញ្ញាតអោយមន្ត្រីរាជការស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.តត ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការដាក់មន្ត្រីរាជការស៊ីវិលឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស
- យោងតាមសំណើរបស់រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ស ម្រេ ច

មាត្រា ១ : ត្រូវបានអនុញ្ញាតឱ្យលោកស្រី **អ៊ុខ ពុទ្ធារី** វរមន្ត្រី ថ្នាក់លេខ ៩ មន្ត្រីបំរើការងារនៅនាយកដ្ឋានផែនការ និងសហប្រតិបត្តិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី ស្ថិតក្នុងភាពទំនេរគ្មានបៀវត្សរយៈពេល ០១ ឆ្នាំ គិតចាប់ពីថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៧ ដល់ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៨។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤១៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/២៧៥ ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៦/២៥ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តនៃការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន ០៧រូប នៅលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន អោយបំពេញមុខងារដូចតទៅ :

១- ឯកឧត្តម ឡ៊ី ជា ជាអនុប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុក-កិច្ចការព្រំដែន ទទួលការងារនីតិកម្ម បន្ថែមលើមុខងារបច្ចុប្បន្ន ។

២- លោក ខ៊ាំ ចណ្ណារិន្ទ ជាអនុប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុក-កិច្ចការព្រំដែន ទទួលការងារដោះស្រាយបាតុភាព និងអភិវឌ្ឍន៍ មានឋានៈស្មើ អគ្គនាយករង ។

៣-លោក ឡាយ សៀវឆី ជាប្រធានផ្នែកបច្ចេកទេសវាស់វែង មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

៤- លោក **ឃាស់ ផល្លារិទ្ធ** ជាប្រធានផ្នែកដោះស្រាយបាតុភាពតាមបណ្តោយព្រំដែន មានឋានៈស្មើប្រធាននាយកដ្ឋាន ។

៥- លោក **គុយ ទិសុទ្ធ** ជាប្រធានផ្នែកអភិវឌ្ឍន៍តាមបណ្តោយព្រំដែន មានឋានៈស្មើប្រធាននាយកដ្ឋាន ។

៦- លោក **ឃុំ ប៊ុណ្ណារ័ទ្ធ** ជាប្រធានផ្នែកប្រព័ន្ធពត៌មានភូមិសាស្ត្រ និងផែនទី មានឋានៈស្មើប្រធាននាយកដ្ឋាន ។

៧- លោក **ស៊ា ម៉ៅ** ជាប្រធានផ្នែកនីតិកម្ម មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា ៣
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ ៧០ ប្រក/រប

លិខិតចូល
ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ 2007

ប្រកាស

ស្តីពី

ការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/៩៤/០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រម លេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យ លេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យ លេខ ៤០ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុង នៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យ លេខ ៧១ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

សម្រេច

ប្រការ ១ .-

ប្រកាសនេះមានគោលដៅកំណត់ការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សំដៅបង្កើនប្រសិទ្ធភាពការងារនៅតាមអគ្គនាយកដ្ឋាន នាយកដ្ឋាន មន្ទីរតាមបណ្តាខេត្ត ក្រុង និងអង្គភាពក្រោមឱវាទក្រសួង ។

ប្រការ ២ .-

នាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវអនុវត្តមុខងារឯករាជ្យ ដើម្បីពិនិត្យ វិភាគ វាយតម្លៃលើសកម្មភាពរបស់អគ្គនាយកដ្ឋាន នាយកដ្ឋាន មន្ទីរតាមបណ្តាខេត្ត ក្រុង និងអង្គភាពក្រោមឱវាទក្រសួងដោយផ្តល់នូវអនុសាសន៍មតិយោបល់កែលំអ សំដៅជួយឱ្យអង្គភាពទាំងនោះ បំពេញភារកិច្ចប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

មន្ត្រីរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង មានសិទ្ធិពេញលេញក្នុងការត្រួតពិនិត្យលើគ្រប់សកម្មភាព រាល់បញ្ជីកត់ត្រា ទ្រព្យសម្បត្តិ និងបុគ្គលិករបស់គ្រប់អង្គភាព ។ មន្ត្រីសវនកម្មផ្ទៃក្នុង ត្រូវមានភាពស្ទាត់ជំនាញនៃវិជ្ជាជីវៈ សុចរិត ស្មោះត្រង់ និងមិនអនុញ្ញាតឱ្យលាតត្រដាង ផ្សព្វផ្សាយ នាំយកព័ត៌មាន ស្តីពីសវនកម្មទៅមជ្ឈដ្ឋានខាងក្រៅ ។

ប្រការ ៣ .-

នាយកដ្ឋានសវនកម្មផ្ទៃក្នុងមានភារកិច្ច ដូចខាងក្រោម ៖

១. រៀបចំផែនការសវនកម្មប្រចាំឆ្នាំ ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ និងសម្រេច ។

២. ពិនិត្យឡើងវិញលើមុខងារ សកម្មភាពកិច្ចប្រតិបត្តិការ និងកម្មវិធីរបស់អង្គភាពក្នុងការិយបរិច្ឆេទសមស្របរបស់ថ្នាក់ដឹកនាំ ក្នុងការអនុវត្តឱ្យបានត្រឹមត្រូវលើការបង្កើតផែនការ ការតម្រង់ទិស ការចាត់ចែង និងការត្រួតពិនិត្យដោយផ្អែកតាមគោលការណ៍ណែនាំគោលនយោបាយ នីតិវិធីនៃការគ្រប់គ្រងឱ្យបានត្រឹមត្រូវតាមគោលដៅរបស់អង្គភាព ។

៣. កំណត់នូវភាពសមស្របគ្រប់គ្រាន់ និងការផ្តល់លទ្ធផលល្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ផ្នែកគណនេយ្យ រដ្ឋបាល និងកិច្ចប្រតិបត្តិការរបស់អង្គភាព ។

៤. ពិនិត្យឡើងវិញនូវភាពដែលអាចជឿទុកចិត្តបាន ភាពទាន់ពេលវេលា និងភាពច្បាស់លាស់នៃព័ត៌មានហិរញ្ញវត្ថុ និងកិច្ចប្រតិបត្តិការ ព្រមទាំងវិធីសាស្ត្រដែលប្រើប្រាស់ ដើម្បីកំណត់អត្តសញ្ញាណ វាស់វែងចំណាត់ថ្នាក់អំពីព័ត៌មានទាំងនោះ ។

៥. ពិនិត្យឡើងវិញ និងសំណូមពរឱ្យមានការផ្លាស់ប្តូរ កែលំអតាមការចាំបាច់លើប្រព័ន្ធដែលបានបង្កើត ដើម្បីធានាបានតាមគោលនយោបាយ ផែនការ នីតិវិធី ច្បាប់ និងបទបញ្ញាទាំងឡាយដែលមានឥទ្ធិពលសំខាន់លើកិច្ចប្រតិបត្តិការ និងរបាយការណ៍ ។

៦. ពិនិត្យឡើងវិញលើការគ្រប់គ្រង ថែទាំ ការពារ និងផ្ទៀងផ្ទាត់ទ្រព្យសម្បត្តិដែលមានឱ្យបានត្រឹមត្រូវ ។

៧. វាយតម្លៃភាពសន្សំសំចៃ និងប្រសិទ្ធភាពលើការប្រើប្រាស់ធនធាន និងកំណត់ការកែលំអលើការអនុវត្តកិច្ចប្រតិបត្តិការ និងផ្តល់អនុសាសន៍ ។

៨. ពិនិត្យឡើងវិញលើកិច្ចប្រតិបត្តិការកម្មវិធី និងគម្រោងចំណាយមូលធនលើលទ្ធផលការងារវិជ្ជមាន ឬអវិជ្ជមានតាមគោលបំណង គោលដៅដែលបានដាក់ចេញ និងតាមផែនការដែលបានកំណត់ ។

៩. ចូលរួមបង្កើតផែនការ ការអភិវឌ្ឍ ការអនុវត្ត និងកិច្ចប្រតិបត្តិការលើប្រព័ន្ធកុំព្យូទ័រសំខាន់ៗ ដើម្បីធានា ៖

ក. តម្រូវការរបស់អ្នកប្រើប្រាស់បានច្បាស់លាស់ ។

ខ. ការបញ្ចូលការត្រួតពិនិត្យផ្ទៃក្នុងសមស្របទៅក្នុងប្រព័ន្ធកុំព្យូទ័រ ។

គ. ការប្រព្រឹត្តទៅក្នុងដំណាក់កាលសមស្របនៃការសាកល្បងប្រព័ន្ធកុំព្យូទ័រ ។

ឃ. ការកត់ត្រាឱ្យបានពេញលេញ និងត្រឹមត្រូវតាមប្រព័ន្ធកុំព្យូទ័រ ។

១០. ធ្វើសវនកម្មតាមប្រព័ន្ធកុំព្យូទ័រ តាមការិយបរិច្ឆេទ និងធ្វើការវាយតម្លៃលើប្រព័ន្ធដំណើរការទិន្នន័យសំខាន់ៗក្រោយពេលដំឡើងរួច ដើម្បីកំណត់ប្រព័ន្ធទាំងនេះ ឱ្យឆ្លើយតបតាមគោលបំណង និងគោលដៅដែលបានគ្រោងទុក ហើយទទួលបានលទ្ធផល មានសុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់ ។

១១. ពិនិត្យឡើងវិញលើនីតិវិធី និងការអនុវត្ត ដើម្បីធានាថា វិធានការដែលបានដាក់ចេញមានគោលបំណងបង្ការការកេងបន្លំ និងដើម្បីរកឃើញបានទាន់ពេលនូវវិធានការដែលមានគោលបំណងកេងបន្លំ ។

១២. ពិនិត្យឡើងវិញលើការអនុវត្តតាមគោលការណ៍ណែនាំ និងការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល ស្តីពីឥរិយាបថ និងក្រមសីលធម៌ចំពោះមន្ត្រីរាជការ ។

១៣. សម្របសម្រួលការងារសវនកម្មផ្ទៃក្នុងជាមួយអាជ្ញាធរសវនកម្មជាតិ ដើម្បីធានាទំហំការងារឱ្យបានគ្រប់គ្រាន់ និងកាត់បន្ថយការងារស្ទួនគ្នា ។

១៤. ធ្វើរបាយការណ៍ និងសេចក្តីសន្និដ្ឋាននៃការធ្វើសវនកម្ម ជូនរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជូនអង្គភាពដែលទទួលបន្ទុកកែលំអតាមអនុសាសន៍នីមួយៗក្រោមឱវាទក្រសួង និងផ្ញើជូនអាជ្ញាធរសវនកម្មជាតិ ។ របាយការណ៍ និងសេចក្តីសន្និដ្ឋាននៃការធ្វើសវនកម្ម ត្រូវចែងអំពី ៖

ក. សកម្មភាពកែលំអតាមអនុសាសន៍សំខាន់ៗរបស់សវនកម្មផ្ទៃក្នុង ។

ខ. សកម្មភាពសវនកម្មត្រូវផ្តោតលើហានិភ័យ បង្កើនភាពសន្សំសំចៃ ប្រសិទ្ធភាព និងការផ្តល់លទ្ធផលល្អក្នុងកិច្ចប្រតិបត្តិការ ។

គ. ការសម្របសម្រួលការងាររវាងអាជ្ញាធរសវនកម្មជាតិ និងសវនកម្មផ្ទៃក្នុង ដើម្បីជៀសវាងការធ្វើសវនកម្មស្ទួនគ្នា ។

ឃ. ភាពសមស្របច្បាស់លាស់គ្រប់គ្រាន់ នៃផែនការសវនកម្មផ្ទៃក្នុង ។

ង. ការរារាំងលើព័ត៌មាន និងបញ្ជី ។

១៥. វាយតម្លៃផែនការ ឬសកម្មភាពកែលំអ លើចំណុចរកឃើញរបស់សវនកម្មផ្ទៃក្នុង ដោយពិភាក្សាឱ្យស្របតាមសំណូមពរដែលអាចទទួលយកបាន ប្រសិនបើ សកម្មភាពកែលំអនេះមិនមានលក្ខណៈសមស្រប ។

១៦. អនុវត្តរាល់ការងារ និងភារកិច្ចផ្សេងៗទៀតដែលក្រសួងប្រគល់ជូន ។

ប្រការ ៤ .-

នាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការទៅតាមការចាំបាច់ ។

ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុងត្រូវរាយការណ៍ដោយផ្ទាល់ជូនរដ្ឋមន្ត្រី ។

ប្រការ ៥ .-

នាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានការិយាល័យចំណុះ ដូចខាងក្រោម ៖

- ការិយាល័យសវនកម្មទី ១
- ការិយាល័យសវនកម្មទី ២
- ការិយាល័យសវនកម្មទី ៣
- ការិយាល័យសវនកម្មទី ៤ ។

ការិយាល័យនីមួយៗដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការទៅតាមការចាំបាច់ ។

ប្រការ ៦ .-

ការិយាល័យសវនកម្មទី ១ ទទួល ៖ ...

១. ភារកិច្ចរបស់នាយកដ្ឋាន ដូចខាងក្រោម ៖

- កិច្ចការរដ្ឋបាលទូទៅ
- គ្រប់គ្រងការងារធនធានមនុស្ស
- គ្រប់គ្រងចំណូលចំណាយថវិកា
- គ្រប់គ្រងទ្រព្យសម្បត្តិ បញ្ជីសារពើភណ្ឌ
- កិច្ចការនីតិកម្ម សម្របសម្រួលការងារវិវាទ និងបណ្តឹងនានា ។

២. ខុសត្រូវធ្វើសវនកម្ម ៖

- អគ្គនាយកដ្ឋានរដ្ឋបាល និងនាយកដ្ឋានចំណុះ
- អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម និងនាយកដ្ឋានចំណុះ
- អគ្គនាយកដ្ឋាន សុរិយោដី និងភូមិសាស្ត្រ និងនាយកដ្ឋានចំណុះ
- អគ្គនាយកដ្ឋានសំណង់ និងនាយកដ្ឋានចំណុះ
- ខុទ្ទកាល័យ
- អធិការដ្ឋាន
- មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ
- យន្តការការងារមួយចំនួន មានជាអាទិ៍ ៖
  - គំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី
  - អគ្គលេខាធិការដ្ឋាន សម្បទានដីសង្គមកិច្ច
  - អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាគោលនយោបាយដីធ្លី
  - លេខាធិការដ្ឋាន គណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

ប្រការ ៧ .-

ការិយាល័យសវនកម្មទី ២ ទទួលខុសត្រូវធ្វើសវនកម្មមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ក្រុងភ្នំពេញ ក្រុងព្រះសីហនុ ក្រុងកែប ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តកំពត និងខេត្តកោះកុង ។

ប្រការ ៨ .-

ការិយាល័យសវនកម្មទី ៣ ទទួលខុសត្រូវធ្វើសវនកម្មមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពង់ឆ្នាំង ខេត្តពោធិសាត់ ខេត្តបាត់ដំបង ក្រុងប៉ៃលិន ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តសៀមរាប និងព្រះវិហារ ។

ប្រការ ៩.-

ការិយាល័យសវនកម្មទី ៤ ទទួលខុសត្រូវធ្វើសវនកម្មមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តស្ទឹងត្រែង ខេត្តក្រចេះ ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី ។

ប្រការ ១០.-

ការិយាល័យសវនកម្មនីមួយៗមានភារកិច្ច ដូចតទៅ ៖

- រៀបចំផែនការសវនកម្មប្រចាំឆ្នាំ ជូនប្រធាននាយកដ្ឋានពិនិត្យ និងសម្រេច
- ផ្តល់របាយការណ៍សកម្មភាពការងាររបស់ខ្លួន ជូនប្រធាននាយកដ្ឋានពិនិត្យ និងផ្តល់ការណែនាំ
- ធ្វើសវនកម្មលើមុខងារ រចនាសម្ព័ន្ធ ទស្សនទាន យុទ្ធសាស្ត្រ កម្មវិធី វិធានការ បទបញ្ញា មធ្យោបាយ និងការចាត់តាំងការងាររបស់អង្គភាព ឱ្យស្របតាមនីតិវិធី បច្ចុប្បន្នភាពនៃសមោកាស គោលការណ៍ណែនាំ និងកម្មវត្ថុរបស់អង្គភាព
- ធ្វើសវនកម្មលើយុទ្ធសាស្ត្រ និងភាពសមស្របនៃការគ្រប់គ្រងធនធានមនុស្ស ដូចជា រចនាសម្ព័ន្ធ ចំនួនជំនាញវិជ្ជាជីវៈ ឋានៈ តួនាទី ការលើកទឹកចិត្តស្របតាមនីតិវិធី បច្ចុប្បន្នភាពនៃសមោកាស គោលការណ៍ណែនាំ កម្មវត្ថុរបស់អង្គភាព និងតាមច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- ធ្វើសវនកម្មលើយុទ្ធសាស្ត្រ វិធីសាស្ត្រ ភាពត្រឹមត្រូវ ភាពទាន់ពេល ភាពគ្រប់ជ្រុងជ្រោយ និងស្តង់ដានៃប្រព័ន្ធត្រួតពិនិត្យ ប្រព័ន្ធកត់ត្រាព័ត៌មាន ទិន្នន័យ កិច្ចបញ្ជិកាគណនេយ្យ និងរបាយការណ៍
- ធ្វើសវនកម្មលើការអនុវត្តច្បាប់ បទបញ្ញា វិន័យ ថវិកា និងអភិបាលកិច្ចល្អ នៅក្នុងប្រតិបត្តិការហិរញ្ញវត្ថុ ពិសេសការគៀងគរ និងគ្រប់គ្រងចំណូល ចំណាយថវិកា ហិរញ្ញប្បទាន បំណុល និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- ចូលរួមបង្កើតផែនការអភិវឌ្ឍន៍ និងធ្វើសវនម្មលើការប្រើប្រាស់កុំព្យូទ័រក្នុងការកត់ត្រា និងរក្សាទិន្នន័យ ការត្រួតពិនិត្យផ្ទៃក្នុង និងកិច្ចប្រតិបត្តិការនានា ដោយធានាភាពសមស្របតាមតម្រូវការ គោរពតាមគោលដៅ ដើម្បីទទួលបានលទ្ធផលប្រកបដោយសុវត្ថិភាព និងមានប្រសិទ្ធភាពខ្ពស់
- ធ្វើសវនកម្មពេលមានបណ្តឹង និងប្រមូល តាមដានជាប្រចាំនូវឯកសារគតិយុត្ត និងសកម្មភាពកែទម្រង់ហិរញ្ញវត្ថុសាធារណៈរបស់អង្គភាពនីមួយៗ
- រក្សារបាយការណ៍សវនកម្មឱ្យបានល្អសម្រាប់ជាមូលដ្ឋានតាមដាន ផ្ទៀងផ្ទាត់លើវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍កែលំអ ដែលបានផ្តល់ជូនអង្គភាពនានា ///

- ធ្វើរបាយការណ៍ សេចក្ដីសន្និដ្ឋានអំពីការធ្វើសវនកម្មអង្គភាពក្រោមឱវាទក្រសួង និងអនុសាសន៍ដើម្បីកែលំអអង្គភាពនោះ ជូនប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង
- សហការជាមួយស្ថាប័ននានា សំដៅកសាងមូលដ្ឋានព័ត៌មានឱ្យបានគ្រប់ជ្រុងជ្រោយដើម្បីវាយតម្លៃឱ្យបានសុក្រឹត
- អនុវត្តរាល់ការងារ និងភារកិច្ចផ្សេងទៀត ដែលនាយកដ្ឋានប្រគល់ឱ្យ។

ប្រការ ១១ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ១២ .-

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង គ្រប់ប្រធាននាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ ឧសភា ឆ្នាំ២០០៧

ទេសរដ្ឋមន្ត្រី

អ៊ឹម ឈុនលឹម

<u>កន្លែងទទួល :</u>
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- គ្រប់មន្ទីរ ដ.ន.ស.ស.ខេត្ត ក្រុង
- ដូចប្រការ ១២
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ...៣៧០.ដន.ក្រ.ប្រក.ដនស ចុះថ្ងៃទី ..០៩.... ខែ ឧសភា ឆ្នាំ ២០០៧

អង្គការលេខរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ០០០៤ សរ ណន

លិខិតចូល
ថ្ងៃទី ៣០ ខែឧសភា ឆ្នាំ 20០៧

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែឧសភា ឆ្នាំ ២០០៧

សេចក្តីណែនាំ
ស្តីពី
ការចុះសៀវភៅអត្រានុកូលដ្ឋាន ឱ្យមាននិរន្តរភាពក្រោយបញ្ចប់យុទ្ធនាការ ចុះសៀវភៅអត្រានុកូលដ្ឋានចល័ត

ការចុះសៀវភៅអត្រានុកូលដ្ឋាន គឺជាការផ្តល់នូវឯកសារគតិយុត្តិដ៏សំខាន់ចាំបាច់ ជូនប្រជាពលរដ្ឋទាក់ទងនឹងកំណើត អាពាហ៍ពិពាហ៍ និង មរណភាព។ ឯកសារគតិយុត្តិទាំងនេះ គឺជាឯកសារ និងជាភស្តុតាងដ៏មានតម្លៃបំផុតក្នុងជីវិតរបស់មនុស្សម្នាក់ៗសម្រាប់បញ្ជាក់អំពីអត្តសញ្ញាណ និង ស្ថានភាពស៊ីវិលរបស់ខ្លួនក្នុងគោលដៅលើកស្ទួយនូវសិទ្ធិ ករណីយកិច្ចរបស់ប្រជាពលរដ្ឋម្នាក់ ៗ នៅក្នុងគ្រួសារខ្លួន និង សង្គមជាតិ ។ ក្នុងសង្គមប្រជាធិបតេយ្យ និងនីតិរដ្ឋ ប្រជាពលរដ្ឋគ្រប់ៗរូបតែងតែប្រើប្រាស់ឯកសារអត្រានុកូលដ្ឋានសំរាប់ការពារសិទ្ធិ សេរីភាព ផលប្រយោជន៍ និង កាតព្វកិច្ចនានា ក្នុងសង្គម ។

អនុលោមតាមអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពី អត្រានុកូលដ្ឋាន អនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន អនុក្រឹត្យលេខ ៨៩ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីការកែសម្រួលចំណុច " ក " និង " ខ " មាត្រា ៥៩ថ្មីស្ទួន នៃអនុក្រឹត្យលេខ ១០៦ អនក្រ. បក ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៥ ស្តីពី ការកែសម្រួលចំណុច " ក " និង " ខ " មាត្រា ៥៩ ថ្មី ស្ទួន ។

ក្រោយពីយុទ្ធនាការ នៃការចុះសៀវភៅអត្រានុកូលដ្ឋានចល័ត ត្រូវបានបញ្ចប់នៅថ្ងៃទី [illegible] ឆ្នាំ ២០០៦ និង ដើម្បីឱ្យដំណើរការ នៃការចុះសៀវភៅអត្រានុកូលដ្ឋានអនុវត្តទៅបានល្អប្រសើរ និង មាននិរន្តរភាព [illegible]មហាផ្ទៃ សូមធ្វើការណែនាំ ដូចខាងក្រោម ÷

I- អំពីភារកិច្ច :

១- ថ្នាក់ក្រសួង :

នាយកដ្ឋានរដ្ឋបាលទូទៅ នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ជាសេនាធិការឱ្យក្រសួង លើការងារស្ថិតិ និង អត្រានុកូលដ្ឋាន និង មានភារកិច្ច ដូចខាងក្រោម ÷

- សិក្សាស្រាវជ្រាវរៀបចំលិខិតបទដ្ឋាន សេចក្តីណែនាំ ផែនការណែនាំ ពាក់ព័ន្ធការងារអត្រានុកូលដ្ឋាន

- ណែនាំ សំរបសំរួល និង ត្រួតពិនិត្យការអនុវត្តការចុះសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទ

- ត្រួតពិនិត្យ និង បូកសរុបស្ថិតិប្រជាពលរដ្ឋទូទាំងប្រទេស

- បូកសរុបស្ថិតិប្រជាពលរដ្ឋ ដែលបានចុះសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទ នៅគ្រប់ខេត្ត ក្រុង ទូទាំងប្រទេសរាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ

- លើកផែនការស្នើសុំបោះពុម្ពសៀវភៅ និង ក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទ សម្រាប់ផ្តល់ជូនដល់ខេត្ត ក្រុង អោយបានគ្រប់គ្រាន់ និង ទាន់ពេលវេលា

- សហការរៀបចំការបណ្តុះបណ្តាល ការកសាងសមត្ថភាព និង ការអប់រំសាធារណជនអំពីការងារអត្រានុកូលដ្ឋាន

- រៀបចំបញ្ចូលទិន្នន័យអត្រានុកូលដ្ឋានក្នុងប្រព័ន្ធពត៌មានវិទ្យា

- អនុវត្តការងារចាំបាច់ផ្សេងៗទៀត ដែលទាក់ទងនឹងការងារស្ថិតិ និង អត្រានុកូលដ្ឋាន ។

២- ថ្នាក់ខេត្ត ក្រុង :

អភិបាលខេត្ត ក្រុង ទទួលខុសត្រូវក្នុងការត្រួតពិនិត្យការអនុវត្តការងារស្ថិតិ និង អត្រានុកូលដ្ឋាន នៅខេត្ត ក្រុង របស់ខ្លួន ដោយមានការិយាល័យស្ថិតិ និង អត្រានុកូលដ្ឋាននៃសាលាខេត្ត ក្រុងជាសេនាធិការ និង មានភារកិច្ច :

- ត្រួតពិនិត្យ និង បូកសរុបស្ថិតិប្រជាពលរដ្ឋទូទាំងខេត្ត ក្រុង និង ផ្ញើរបាយការណ៍មកក្រសួងមហាផ្ទៃតាមការកំណត់

- ត្រួតពិនិត្យការអនុវត្តការចុះសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទនៅតាមស្រុក ខណ្ឌ និង ឃុំ សង្កាត់

- បូកសរុបស្ថិតិប្រជាពលរដ្ឋដែលបានចុះសៀវភៅអត្រានុកូលដ្ឋានគ្រប់ភេទប្រចាំខែ និង ផ្ញើរបាយការណ៍ទៅក្រសួងមហាផ្ទៃ (នាយកដ្ឋានរដ្ឋបាលទូទៅ នៃអគ្គនាយកដ្ឋាន រដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ) រៀងរាល់ថ្ងៃទី ១៥ នៃខែបន្ទាប់នីមួយៗ

- លើកគំរោងទៅក្រសួងមហាផ្ទៃ ដើម្បីស្នើសុំសៀវភៅ និង ក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទ សំរាប់ផ្តល់ឱ្យ ស្រុក ខណ្ឌ ធ្វើការបែងចែកដល់ឃុំ សង្កាត់ និង ធ្វើរបាយការណ៍បូកសរុបការប្រើប្រាស់ ឱ្យបានទាន់ពេលកំណត់

- សហការរៀបចំការបណ្តុះបណ្តាល ការកសាងសមត្ថភាព និង ការអប់រំសាធារណជនអំពីការងារអត្រានុកូលដ្ឋាន

- ផ្សព្វផ្សាយលិខិតបទដ្ឋាន សេចក្តីណែនាំ ផែនការណែនាំ អំពីការងារអត្រានុកូលដ្ឋានដល់ស្រុក ខណ្ឌ ឃុំ សង្កាត់ចំណុះ

- ធ្វើការវាយតំលៃការអនុវត្តការងារស្ថិតិ និង អត្រានុកូលដ្ឋានក្នុងខេត្ត ក្រុងរបស់ខ្លួន

- អនុវត្តការងារចាំបាច់ផ្សេងៗទៀត ដែលទាក់ទងនឹងការងារស្ថិតិ និង អត្រានុកូលដ្ឋាន ។

៣- ថ្នាក់ស្រុក ខណ្ឌ :

អភិបាលស្រុក ខណ្ឌ ទទួលខុសត្រូវក្នុងការត្រួតពិនិត្យ និង អនុវត្តការងារស្ថិតិ និង អត្រានុកូលដ្ឋាន នៅស្រុក ខណ្ឌ របស់ខ្លួន ដោយមានការិយាល័យរដ្ឋបាលទូទៅនៃសាលាស្រុក ខណ្ឌជាសេនាធិការ មានភារកិច្ចដូចខាងក្រោម ÷

- ត្រួតពិនិត្យ និង បូកសរុបស្ថិតិប្រជាពលរដ្ឋទូទាំងស្រុក ខណ្ឌ និង ផ្ញើរបាយការណ៍មកខេត្ត ក្រុងតាមការកំណត់

- បូកសរុបស្ថិតិប្រជាពលរដ្ឋដែលបានចុះសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទប្រចាំខែនីមួយៗ តាមឃុំ សង្កាត់ចំណុះ និង ផ្ញើទៅការិយាល័យស្ថិតិ និង អត្រានុកូលដ្ឋាននៃសាលាខេត្ត ក្រុង រៀងរាល់ថ្ងៃទី ១០ នៃខែបន្ទាប់ នីមួយៗ

- លើកគំរោងទៅសាលាខេត្ត ក្រុង ដើម្បីសុំសៀវភៅ និង ក្រដាសអត្រានុកូលដ្ឋានសម្រាប់បែងចែកជូន ឃុំ សង្កាត់ និង បូកសរុបការប្រើប្រាស់សៀវភៅ និង ក្រដាសអត្រានុកូលដ្ឋាន ផ្ញើមកខេត្ត ក្រុងតាមការកំណត់

- ចុះចំនួនសន្លឹក លេខរៀងសន្លឹកសៀវភៅអត្រានុកូលដ្ឋាន ចុះហត្ថលេខាពេញ និង សង្ខេបរបស់អភិបាលស្រុក ខណ្ឌ បោះត្រា មុននឹងបែងចែកឱ្យឃុំ សង្កាត់ យកទៅប្រើប្រាស់

- ត្រួតពិនិត្យជាប្រចាំការអនុវត្តការចុះសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទនៅតាមឃុំ សង្កាត់

- ត្រួតពិនិត្យរាល់បញ្ជីក្នុងសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទ ដែលឃុំ សង្កាត់ផ្ញើមកស្រុក ខណ្ឌ ពេលដាច់ឆ្នាំនីមួយៗ ឱ្យបានត្រឹមត្រូវតាមការណែនាំរបស់ក្រសួងមហាផ្ទៃ

- រក្សាទុកដាក់សៀវភៅអត្រានុកូលដ្ឋាន ឱ្យបានគង់វង្សនៅសាលាស្រុក ខណ្ឌ មួយច្បាប់ តាមប្រភេទនីមួយៗ និង មួយច្បាប់ទៀតដូចគ្នា ផ្ញើទៅតុលាការខេត្ត ក្រុង សាមី

- ចេញសេចក្តីចម្លង ឬ សម្រង់ នៃអត្រានុកូលដ្ឋានគ្រប់ប្រភេទជូនដល់ប្រជាពលរដ្ឋ ដែលមកសុំចម្លងឆ្នាំដែលកន្លងផុត

- ផ្សព្វផ្សាយលិខិតបទដ្ឋាន សេចក្តីណែនាំ ផែនការណែនាំ អំពីការងារអត្រានុកូលដ្ឋានដល់ឃុំ សង្កាត់ចំណុះ

- ធ្វើការវាយតំលៃ ការអនុវត្តការងារស្ថិតិ និង អត្រានុកូលដ្ឋានក្នុងស្រុក ខណ្ឌរបស់ខ្លួន

- អនុវត្តការងារចាំបាច់ផ្សេងៗទៀត ដែលទាក់ទងនឹងការងារស្ថិតិ និង អត្រានុកូលដ្ឋាន ។

៤- ថ្នាក់ឃុំ សង្កាត់ :

ក្រុមប្រឹក្សាឃុំ សង្កាត់ ទទួលខុសត្រូវអំពីការងារអត្រានុកូលដ្ឋានក្នុងដែនដីឃុំ សង្កាត់ ដែលខ្លួនគ្រប់គ្រង មេឃុំ ចៅសង្កាត់ ជាមន្ត្រីអត្រាកូលដ្ឋាន ។ មន្ត្រីអត្រានុកូលដ្ឋានមានភារកិច្ច ÷

- លើកគម្រោងស្នើសុំសៀវភៅ និង ក្រដាសអត្រានុកូលដ្ឋានមកសាលាស្រុក ខណ្ឌ សម្រាប់ប្រើប្រាស់នៅក្នុងឃុំ សង្កាត់របស់ខ្លួន

- ចលនាប្រជាពលរដ្ឋរស់នៅក្នុងឃុំ សង្កាត់របស់ខ្លួនអោយមកសុំចុះសៀវភៅអត្រានុកូលដ្ឋានអោយបានគ្រប់ៗគ្នា និង ទាន់ពេលវេលា

- ទទួលពិនិត្យកត់ត្រារឿងហេតុសំខាន់ៗទាក់ទងទៅនឹងកំណើត អាពាហ៍ពិពាហ៍ មរណភាពផ្សេងៗទាំងឡាយចុះនៅក្នុងសៀវភៅអត្រានុកូលដ្ឋាន

- ចេញសេចក្តីចម្លង ឬ សម្រង់នៃអត្រានុកូលដ្ឋានដែលមាននៅឆ្នាំដែលមិនទាន់ដាច់

- អនុញ្ញាតអោយរៀបអាពាហ៍ពិពាហ៍ ធ្វើបុណ្យបូជា ឬ បញ្ចុះសព

- ទទួលខុសត្រូវ ចំពោះសំបុត្រអត្រានុកូលដ្ឋានដែលខ្លួនបានអនុវត្ត

- ចុះហត្ថលេខា និង បោះត្រាលើសំបុត្រអត្រានុកូលដ្ឋាន

- កែតម្រូវ ឬ បដិសេធអត្រានុកូលដ្ឋាន តាមអំណាចសាលក្រមស្ថាពររបស់តុលាការ ឬតាមបទប្បញ្ញត្តិនៃច្បាប់

- ថែរក្សាទុកដាក់សៀវភៅអត្រានុកូលដ្ឋាន តាមប្រភេទអោយបានគត់មត់ល្អ ងាយស្រួលក្នុងការតាមដាន និង ការគ្រប់គ្រង

- បិទសៀវភៅ និង បញ្ជូនសៀវភៅអត្រានុកូលដ្ឋានឆ្នាំដែលដាច់ទៅ យកទៅតម្កល់ទុកនៅសាលាស្រុក ខណ្ឌផ្ទាល់មួយច្បាប់ និង នៅតុលាការខេត្ត ក្រុង សាមីមួយច្បាប់

- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ ឱ្យបានយល់ដឹងពីកាតព្វកិច្ចរបស់ខ្លួនចំពោះអត្រានុកូលដ្ឋាន និង បង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋ ដែលមកទំនាក់ទំនងពីការងារអត្រានុកូលដ្ឋាន

- ធ្វើរបាយការណ៍អំពី កំណើត អាពាហ៍ពិពាហ៍ មរណភាព ចំនួនគ្រួសារ ចំនួនប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ ជារៀងរាល់ខែ នៅថ្ងៃទី ៥ នៃខែបន្ទាប់ និង រាល់ដំណាច់ឆ្នាំនីមួយៗ ផ្ញើទៅសាលាស្រុក ខណ្ឌ សាមី

- សហការជាមួយសមត្ថកិច្ចនៅមូលដ្ឋាន អំពីការងារអត្រានុកូលដ្ឋានក្នុងករណីចាំបាច់ ។

ដើម្បីជួយដល់ក្រុមប្រឹក្សា ឃុំ សង្កាត់ ក្នុងការផ្សព្វផ្សាយអំពីសារៈប្រយោជន៍អត្រានុកូលដ្ឋាន ឱ្យបានជ្រួតជ្រាបដល់ប្រជាពលរដ្ឋនៅក្នុង ឃុំ សង្កាត់ មេឃុំ ចៅសង្កាត់អាចប្រើប្រាស់នូវគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និង កុមារ ឃុំ សង្កាត់ (យោងលើសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃលេខ ០០៥ ស.ណ.ន ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៤ ស្តីពីការបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និង កុមារ ឃុំ សង្កាត់) អោយជួយលើការងារនេះ ដោយបែងចែកនូវភារកិច្ចជូន ដូចខាងក្រោម ÷

- គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និង កុមារក្នុងឃុំ សង្កាត់ ត្រូវជំរុញការផ្សព្វផ្សាយជូនប្រជាពលរដ្ឋ ឱ្យយល់ជ្រួតជ្រាបអំពីសិទ្ធិនារី និង កុមារ ពិសេសអំពីផលប្រយោជន៍ នៃការចុះបញ្ជីអត្រានុកូលដ្ឋាន រួមមាន កំណើត អាពាហ៍ពិពាហ៍ និង មរណភាព និង កាតព្វកិច្ចរបស់ប្រជាពលរដ្ឋ ក្នុងការចុះសៀវភៅអត្រានុកូលដ្ឋាន។

- មេឃុំ ចៅសង្កាត់ ជំទប់ទី២ ឬ ចៅសង្កាត់រងទី២ ត្រូវចលនានៅតាមវត្តអារាម ដើម្បីសំណូមពរដល់ព្រះសង្ឃ អាចារ្យវត្ត នៅពេលមានបុណ្យទាន ឬ ពេលមានពិធីរៀបអាពាហ៍ពិពាហ៍ ឬ ពិធីបុណ្យសព សូមជួយផ្សព្វផ្សាយអោយប្រជាពលរដ្ឋអញ្ជើញទៅចុះសៀវភៅអត្រានុកូលដ្ឋានកំណើតពេលមានទារកកើត ទៅចុះសៀវភៅអាពាហ៍ពិពាហ៍ពេលមានរៀបអាពាហ៍ពិពាហ៍ និង ទៅចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពពេលមានអ្នកស្លាប់ ។

- សមាជិកនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និង កុមារឃុំ សង្កាត់ ត្រូវចុះផ្សព្វផ្សាយផ្ទាល់នៅតាម ភូមិ ឬ តាមផ្ទះប្រជាពលរដ្ឋ ដើម្បីជំរាបអំពីសារៈប្រយោជន៍ នៃការចុះបញ្ជីអត្រានុកូលដ្ឋាន ។

- សមាជិកនៃគណៈកម្មាធិការដែលតំណាងឱ្យមណ្ឌលសុខភាពឃុំ សង្កាត់ ត្រូវផ្សព្វផ្សាយផ្ទាល់នៅមណ្ឌលសុខភាព ឬ មន្ទីរពេទ្យរដ្ឋ និង ឯកជន ពេលមាននារីមកសម្រាលកូននៅមណ្ឌលសុខភាព ឬ មន្ទីរពេទ្យ ពេលចេញទៅវិញត្រូវទៅសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតឱ្យទារក នៅសាលាឃុំ សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ឪពុក ម្តាយទារកកុំឱ្យហួសពី ៣០ថ្ងៃ បន្ទាប់ពីប្រសូតទារក និង នៅពេលមានអ្នកស្លាប់នៅមណ្ឌលសុខភាព ឬ មន្ទីរពេទ្យត្រូវជម្រាបដល់ក្រុមគ្រួសារ ឬ សាច់ញាតិសន្តាននៃសពឱ្យទៅសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព ./.

ក្នុងរយៈពេល ១៥ថ្ងៃ នៅឃុំ សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់អ្នកស្លាប់ ដោយមណ្ឌលសុខភាព ឬ មន្ទីរពេទ្យចេញនូវលិខិតបញ្ជាក់អំពីកំណើត ទារកជូនទៅឪពុក ម្តាយទារក ឬ លិខិតបញ្ជាក់អំពីមរណភាពជូនទៅក្រុមគ្រួសារ ឬ សាច់ញាតិសន្តាននៃអ្នកស្លាប់ ។

- សមាជិកនៃគណៈកម្មាធិការដែលតំណាងឱ្យគ្រូបង្រៀន ត្រូវចលនាជំរាបជូនលោកគ្រូ អ្នកគ្រូ នៅតាមសាលារៀន សំណូមពរឱ្យជួយផ្សព្វផ្សាយជាប្រចាំក្នុងពីរសប្តាហ៍ម្តងដល់សិស្ស ដើម្បីជម្រាបទៅឪពុក ម្តាយ នៃសិស្សទាំងនោះបានជ្រាបពីសារៈប្រយោជន៍ នៃការសុំចុះសៀវភៅអត្រានុកូលដ្ឋាន ។

- ក្នុងករណីដែលឃុំ សង្កាត់ មិនមានបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និង កុមារ មេឃុំ ចៅសង្កាត់ត្រូវចាត់ឱ្យជនបង្គោលទទួលបន្ទុកស្ត្រី និង កុមារ ឱ្យទទួលខុសត្រូវក្នុងការផ្សព្វផ្សាយពីសារៈប្រយោជន៍នៃអត្រានុកូលដ្ឋាន និង កាតព្វកិច្ចរបស់ប្រជាពលរដ្ឋ ចំពោះការចុះសៀវភៅអត្រានុកូលដ្ឋាន ដោយអនុវត្តយកលំនាំតាមការបែងចែកប្រគល់ភារកិច្ចនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និង កុមារ ឃុំ សង្កាត់ ។

ខ្លឹមសារត្រូវជម្រាបជូនដល់ប្រជាពលរដ្ឋអំពី កំណើត អាពាហ៍ពិពាហ៍ មរណភាព មានដូចខាងក្រោម ៖

- ពេលមានទារកកើតឪពុក ម្តាយ ត្រូវទៅរាយការណ៍សុំចុះបញ្ជីអត្រានុកូលដ្ឋានកំណើត កុំឱ្យហួសពី ៣០ថ្ងៃ បន្ទាប់ពីប្រសូតទារក នៅសាលាឃុំ សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ឪពុក ម្តាយទារក ។

- ពេលបុរស នារីសុំរៀបអាពាហ៍ពិពាហ៍ ត្រូវអនុវត្តតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ហើយត្រូវទៅសុំចុះសៀវភៅអាពាហ៍ពិពាហ៍នៅសាលាឃុំ សង្កាត់ នៃលំនៅដ្ឋាននារី ទើបអាពាហ៍ពិពាហ៍នោះ ចាត់ទុកជាត្រឹមត្រូវតាមលក្ខណៈច្បាប់ ។

- ពេលមានអ្នកស្លាប់ ក្រុមគ្រួសារ ឬ សាច់ញាតិសន្តាន នៃអ្នកស្លាប់ត្រូវទៅសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព ក្នុងរយៈពេល១៥ថ្ងៃ នៅសាលាឃុំ សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់អ្នកស្លាប់ ។

៥- នៅភូមិ ៖

- មេភូមិត្រូវចលនាឱ្យប្រជាពលរដ្ឋទៅចុះសៀវភៅអត្រាកូលដ្ឋានមានកំណើត និង មរណភាព ឱ្យបានទាន់ពេលវេលា និង អ្នកបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីរួចហើយ តែមិនទាន់បានចុះបញ្ជីអាពាហ៍ពិពាហ៍ និង អ្នកដែលគ្រោងរៀបចំអាពាហ៍ពិពាហ៍ ដើម្បីឱ្យស្របទៅតាមច្បាប់ ត្រូវទៅសុំចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍នៅសាលាឃុំ សង្កាត់ ខាងលំនៅដ្ឋាននារី ស្របទៅតាមច្បាប់អាពាហ៍ពិពាហ៍ ។

- មេភូមិ ត្រូវចេញលិខិតបញ្ជាក់ទទួលស្គាល់កំណើតទារកឱ្យឪពុក ម្តាយ បើទារកកើតនៅផ្ទះ ដើម្បីឱ្យឪពុកម្តាយទារក មានឯកសារភស្តុតាងសម្រាប់ទៅសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ខ្លួន ដើម្បីចុះសៀវភៅអត្រាកូលដ្ឋានកំណើតឱ្យកូន ។

- មេភូមិត្រូវកត់ត្រាប្រចាំខែនីមួយៗឱ្យបានច្បាស់លាស់នូវស្ថិតិ ៖

. ទារកដែលទើបកើត

. ទារកដែលទើបកើត ហើយ ស្លាប់

. អ្នកដែលបានរួមរស់ជាមួយគ្នាក្នុងស្ថានភាពជាប្តី ប្រពន្ធ មានសំបុត្រអាពាហ៍ពិពាហ៍ ./.

. អ្នកដែលទទួលមរណភាព

- មេភូមិត្រូវស្រង់ស្ថិតិទារក ដែលបានសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតទាន់ពេលកំណត់ ៣០ថ្ងៃ រួចហើយ និង ទារកដែលមិនទាន់បានសុំចុះសៀវភៅអត្រានុកូលដ្ឋាន ហួសពេលកំណត់ ៣០ថ្ងៃ អ្នកទទួលមរណភាព បានសុំចុះសៀវភៅអត្រាកូលដ្ឋានមរណភាពបានទាន់ពេលកំណត់ ១៥ថ្ងៃ និង អ្នកទទួលមរណភាពទុកឱ្យហួសរយៈពេល ១៥ថ្ងៃ ពុំបានសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព អ្នកដែលបានរៀបអាពាហ៍ពិពាហ៍ខាងស៊ីវិល (បានសុំចុះសៀវភៅអត្រា-នុកូលដ្ឋានអាពាហ៍ពិពាហ៍រួច) និង អ្នកដែលរៀបចំអាពាហ៍ពិពាហ៍តាមប្រពៃណី តែមិនទាន់បានរៀបចំអាពាហ៍ពិពាហ៍ខាងស៊ីវិល (ពុំទាន់បានចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍) រួចផ្ញើស្ថិតិនេះទៅសាលាឃុំ សង្កាត់ នៅថ្ងៃទី ០៣ នៃខែបន្ទាប់ ដើម្បីធ្វើការបូកសរុប។ ផ្អែកលើស្ថិតិនេះ មេភូមិត្រូវជម្រុញឱ្យ ឪពុក ម្តាយ ឬ អាណាព្យាបាលទារក ដែលទើបកើតឱ្យទៅចុះបញ្ជីកំណើតនៅសាលាឃុំ សង្កាត់ ឱ្យបានទាន់ពេលវេលា គឺកុំឱ្យហួស ៣០ថ្ងៃ បន្ទាប់ពីទារកប្រសូត ។

II- <u>ការសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត និង មរណភាពក្នុងរយៈពេលកំណត់ :</u>

១- <u>ការសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតក្នុងរយៈពេលកំណត់ ៣០ថ្ងៃ :</u>

(យោងតាមមាត្រា ១៧ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន)

បើមានទារកកើត ឪពុក ឬ ម្តាយ មានកាតព្វកិច្ចត្រូវទៅរាយការណ៍ចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៅសាលាឃុំ ឬ សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ឪពុក ម្តាយទារកនោះ មិនឱ្យហួស ៣០ថ្ងៃ ។ បើឪពុក ម្តាយមានធុរៈទៅមិនបានត្រូវពឹងពាក់សាច់ញាតិសន្តាន ឬ អ្នកនៅជិតខាង ដែលបានឃើញ និង ដឹងឮផ្ទាល់អំពីទារកនោះកើត ឱ្យទៅរាយការណ៍សុំចុះសៀវភៅកំណើតបានទាន់ពេលកំណត់ ។

អ្នកទៅរាយការណ៍សុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត ត្រូវបង្ហាញចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នូវលិខិតស្នាមមួយចំនួនដូចខាងក្រោម ÷

- លិខិតបញ្ជាក់ទទួលស្គាល់កំណើតទារករបស់មន្ទីរពេទ្យ បើទារកកើតនៅមន្ទីរពេទ្យ ឬ
- លិខិតបញ្ជាក់ទទួលស្គាល់កំណើតទារករបស់មេភូមិ បើទារកកើតនៅផ្ទះ ឬ
- កំណត់ហេតុ អំពីកំណើតទារករបស់អ្នកទទួលខុសត្រូវពន្ធនាគារ បើទារកកើតនៅក្នុងពន្ធនាគារ ឬ
- លិខិតបញ្ជាក់របស់ឪពុក ម្តាយ អំពីនាមត្រកូល នាមខ្លួន និង ថ្ងៃ ខែ ឆ្នាំកំណើតរបស់ទារក បើឪពុក ម្តាយទារកពឹងពាក់សាច់ញាតិ ឬ អ្នកជិតខាងអោយទៅរាយការណ៍ជំនួស
- សៀវភៅគ្រួសារដែលមានឈ្មោះឪពុក ម្តាយទារក (ប្រសិនបើមាន)
- សេចក្តីចម្លងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់ឪពុក ម្តាយទារក (ប្រសិនបើមាន) ឬ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ឪពុក ឬ ម្តាយ (ប្រសិនបើមាន) ឬ
- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬ សេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍របស់ឪពុក ម្តាយទារក (ប្រសិនបើមាន)

ទារកដែលបានចុះសៀវភៅអត្រានុកូលដ្ឋានកំណើត ក្នុងរយពេលកំណត់ ៣០ថ្ងៃ មន្ត្រីអត្រានុកូលដ្ឋានត្រូវផ្តល់នូវសំបុត្រកំណើតច្បាប់ដើមមួយសន្លឹកដោយឥតគិតថ្លៃ ។

២- ការសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពក្នុងរយៈពេលកំណត់ ១៥ថ្ងៃ :

(យោងមាត្រា ៣៥, មាត្រា ៣៦, មាត្រា ៣៧, មាត្រា ៣៨ និង មាត្រា ៣៩ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពី អត្រានុកូលដ្ឋាន)

ពេលមានអ្នកស្លាប់ភ្លាម ក្រុមគ្រួសារ ឬ សាច់ញាតិសន្តាន ឬ អ្នកជិតខាង ឬ អ្នកមានភារកិច្ចនៅក្នុងក្រសួង ស្ថាប័ន អង្គភាពរបស់អ្នកស្លាប់ ត្រូវរាយការណ៍ជូនដល់មន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់ នៃទីកន្លែងរស់នៅជាប់លាប់របស់អ្នកស្លាប់ ។

ការចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព និង ចេញសំបុត្រមរណភាព ត្រូវធ្វើក្នុងរយៈពេលយ៉ាងយូរបំផុត ១៥ថ្ងៃ ក្រោយពីទទួលមរណភាព ។

អ្នកទៅរាយការណ៍សុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព ត្រូវបង្ហាញចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នូវលិខិតស្នាមមួយចំនួនដូចខាងក្រោម ÷

- លិខិតជូនដំណឹងមរណភាព បញ្ជាក់ដោយមន្ទីរពេទ្យ បើស្លាប់ក្នុងមន្ទីរពេទ្យ ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយផ្នែកអនាម័យ បើស្លាប់ដោយរោគឆ្លង ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយសមត្ថកិច្ចជំនាញ ប្រសិនបើករណីស្លាប់ទាក់ទងនឹងឃាតកម្ម ឧក្រិដ្ឋកម្ម ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមេភូមិ ដែលអ្នកស្លាប់រស់នៅមុនពេលស្លាប់ ករណីស្លាប់នៅនឹងផ្ទះ ក្នុងភូមិរបស់សព ឬ
- លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវពន្ធនាគារ ករណីអ្នកទោសស្លាប់ក្នុងពន្ធនាគារ ឬ
- លិខិតជូនដំណឹងរបស់អ្នកទទួលខុសត្រូវតាមក្រសួង ស្ថាប័ន ឬ អង្គភាពរបស់អ្នកស្លាប់ ករណីអ្នកស្លាប់នៅក្នុងក្រសួង ស្ថាប័ន ឬ អង្គភាព
- សៀវភៅគ្រួសារដែលមានឈ្មោះអ្នកស្លាប់នៅក្នុងនោះ (ប្រសិនបើមាន)
- សេចក្តីចម្លងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់អ្នកស្លាប់ (ប្រសិនបើមាន)

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវផ្តល់នូវសំបុត្រមរណភាពច្បាប់ដើមមួយសន្លឹក ដោយឥតគិតថ្លៃ ជូនដល់ក្រុមគ្រួសារ ឬ សាច់ញាតិសន្តាន ដែលមករាយការណ៍សុំចុះសៀវភៅមរណភាព ចំពោះអ្នកស្លាប់ក្នុងរយៈពេលកំណត់ ១៥ថ្ងៃ ។

III- ការសុំចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ ចំពោះអ្នកដែលបានរៀបការរៀបអាពាហ៍ពិពាហ៍ ផ្អែកតាមច្បាប់ ស្តីពី អាពាហ៍ពិពាហ៍ និង គ្រួសារ

(យោងមាត្រា ២៨, មាត្រា ២៩, មាត្រា ៣០ និង មាត្រា ៣១ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពី អត្រានុកូលដ្ឋាន)

kmera 11.04.07

បុរស នារី ដែលបានធ្វើប័ណ្ណប្រកាសអាពាហ៍ពិពាហ៍រួចផុតកំណត់១០ថ្ងៃមិនមានការប្តឹងតវ៉ា ដើម្បីធានាឱ្យអាពាហ៍ពិពាហ៍នោះមានលក្ខណៈត្រឹមត្រូវទៅតាមច្បាប់ សាមីខ្លួនទាំងពីររូបត្រូវរៀបអាពាហ៍ពិពាហ៍ខាងស៊ីវិល ដោយត្រូវមកសុំចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍នៅឃុំ សង្កាត់ នៃលំនៅដ្ឋានសាមីខ្លួនខាងនារី ដោយនាំមកជាមួយនូវប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ និង សាក្សីគ្រប់អាយុការចំនួនពីរនាក់ មកបង្ហាញចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ដើម្បីបំពេញបែបបទចុះបញ្ជីអាពាហ៍ពិពាហ៍ តាមគោលការណ៍ សំដៅឱ្យច្បាប់ការពារ សិទ្ធិ ករណីយកិច្ច និង ផលប្រយោជន៍របស់គូស្វាមីភរិយា តរៀងទៅ ។

IV- ការសុំចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ ចំពោះពលរដ្ឋខ្មែរ ដែលបានរស់នៅជាមួយគ្នាក្នុងស្ថានភាពជាប្តី ប្រពន្ធ តែពុំទាន់មានសំបុត្រអាពាហ៍ពិពាហ៍ :

ពលរដ្ឋខ្មែរដែលបានរស់នៅជាមួយគ្នាក្នុងស្ថានភាពជាប្តី ប្រពន្ធ ឬ បានរៀបចំអាពាហ៍ពិពាហ៍តាមប្រពៃណីរួចហើយ តែពុំទាន់មានសំបុត្រអាពាហ៍ពិពាហ៍ប្រើប្រាស់ សាមីខ្លួនទាំងពីររូប ត្រូវប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍(ការរៀបចំអាពាហ៍ពិពាហ៍ខាងស៊ីវិល) នៅសាលាឃុំ សង្កាត់សាមី ដែលខ្លួនរស់នៅពិតប្រាកដបច្ចុប្បន្ន។ ដើម្បីទទួលបាននូវសំបុត្រអាពាហ៍ពិពាហ៍ សាមីខ្លួនទាំងពីររូប ត្រូវមានលិខិតស្នាម ដូចខាងក្រោម ÷

- ពាក្យសុំរៀបអាពាហ៍ពិពាហ៍
- លិខិតបញ្ជាក់ភាពនៅលីវ មេម៉ាយ ពោះម៉ាយ
- សេចក្តីចម្លងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់សាមីខ្លួន (ប្រសិនបើមាន) ឬ
- សៀវភៅគ្រួសាររបស់សាមីខ្លួន (ប្រសិនបើមាន) ឬ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់សាមីខ្លួន (ប្រសិនបើមាន) ។

មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ក្រោយពីពិនិត្យឃើញថា មានឯកសារគ្រប់គ្រាន់ និង ត្រឹមត្រូវហើយ ត្រូវចេញប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ចំនួន ០៣ ច្បាប់ ដោយមួយច្បាប់បិទផ្សាយជាសាធារណៈនៅផ្ទះសាមីខ្លួនទាំងពីររូប មួយច្បាប់បិទនៅសាលាឃុំ សង្កាត់សាមី និង មួយច្បាប់ទៀតរក្សាទុកជាឯកសារនៅសាលាឃុំ សង្កាត់សាមី ។ ក្នុងពេលបិទផ្សាយប័ណ្ណប្រកាសអាពាហ៍ពិពាហ៍រយៈពេល ១០ ថ្ងៃ បើគ្មានការប្តឹងជំទាស់ទេ សាមីខ្លួនទាំងពីររូបអាចទៅសុំចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ (ការរៀបចំអាពាហ៍ពិពាហ៍ខាងស៊ីវិល) បាននៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់សាមី ដោយនាំសាក្សី ០២ រូប ដែលមានអាយុគ្រប់ការ និង មានទីលំនៅពិតប្រាកដទៅជាមួយ ។

V- ការសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត និង មរណភាពហួសរយៈពេលកំណត់ :

១- ការសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតហួសរយៈពេល ៣០ថ្ងៃ :

ពលរដ្ឋខ្មែរដែលបានកើតហើយទុកឱ្យហួសរយៈពេល ៣០ថ្ងៃ ហើយពុំទាន់មានសំបុត្រកំណើតប្រើប្រាស់ សាមីខ្លួន ឬ ឪពុក ឬ ម្តាយ ឬ អាណាព្យាបាល ត្រូវប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត នៅសាលាឃុំ សង្កាត់សាមី ដែលខ្លួនរស់នៅពិតប្រាកដបច្ចុប្បន្ន ដោយនាំទៅជាមួយនូវសាក្សីចំនួន ០២រូប ជានីតិជន ហើយត្រូវមានទីលំនៅពិតប្រាកដមកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

សាមីខ្លួន ឬ ឪពុក ឬ ម្តាយ ឬ អាណាព្យាបាល និង សាក្សី ត្រូវមាននូវលិខិតស្នាមមួយចំនួនដូចខាងក្រោម ÷

- ពាក្យប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើតរបស់សាមីខ្លួន ឬ ឪពុក ឬ ម្តាយ ឬ អាណាព្យាបាល ចំនួន ០១ច្បាប់ ដែលបិទតែមប្រើថ្លៃ ១.០០០ (មួយពាន់) រៀល សំរាប់ប្រជាពលរដ្ឋដែលមានទីលំនៅ នៅខេត្ត រតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ព្រះវិហារ ឧត្តរមានជ័យ និង បិទតែមប្រើថ្លៃ ៤.០០០ (បួនពាន់) រៀល សំរាប់ ប្រជាពលរដ្ឋ ដែលមានទីលំនៅក្រៅពីខេត្តខាងលើ។ ចំពោះការបិទតែមប្រើតម្លៃ ១.០០០ រៀល និង ៤.០០០ រៀល លើពាក្យប្តឹងសុំ គឺជំនួសឱ្យការបង់ប្រាក់ផ្ទាល់។

- លិខិតបញ្ជាក់ទទួលស្គាល់កំណើតទារករបស់មន្ទីរពេទ្យ បើកើតនៅមន្ទីរពេទ្យ ឬ
- លិខិតបញ្ជាក់ទទួលស្គាល់កំណើតទារករបស់មេភូមិ បើកើតនៅផ្ទះ ឬ
- កំណត់ហេតុ ឬ លិខិតបញ្ជាក់ពីប្រធានស្ថាប័ន ឬ អង្គភាព អំពីកំណើតរបស់ទារក ឬ កុមារ បើកើត នៅស្ថាប័ន ឬ អង្គភាព ឬ
- សៀវភៅគ្រួសាររបស់សាមីខ្លួន ឪពុក ម្តាយ និង របស់សាក្សី (ប្រសិនបើមាន) ឬ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់សាមីខ្លួន ឬ ឪពុក ឬ ម្តាយ ឬ អាណាព្យាបាល និង របស់សាក្សី ឬ
- សេចក្តីចម្លងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់ឪពុក ឬ ម្តាយ ឬ អាណាព្យាបាល និង សាក្សី (ប្រសិនបើមាន)
- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬ សេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍របស់ ឪពុក ម្តាយ (ប្រសិនបើមាន)ឬ
- ឯកសារបៀវត្ស ឬ សោធននិវត្ត ឬ សេចក្តីបញ្ជាក់ពីស្ថាប័នសាមីរបស់សាមីខ្លួន បើជាមន្ត្រីរាជការ កងយោធពលខេមរភូមិន្ទ និង កងនគរបាលជាតិ។

២- ការសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពហួសរយៈពេល ១៥ថ្ងៃ :

(យោងមាត្រា៤០ ថ្មី នៃអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៤)

បើមានអ្នកស្លាប់ទុកឱ្យហួសរយៈពេល ១៥ថ្ងៃ ពុំបានទៅរាយការណ៍ចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពទេ ក្រុមគ្រួសារ នៃអ្នកស្លាប់ត្រូវប្តឹងសុំសំបុត្រមរណភាពពី មេឃុំ ចៅសង្កាត់សាមី ដោយបង់ថ្លៃសំបុត្រមរណភាពនេះដល់ អាជ្ញាធរឃុំ សង្កាត់សាមី ចំនួន ១.០០០ (មួយពាន់) រៀល សំរាប់ប្រជាពលរដ្ឋមានទីលំនៅ នៅខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ព្រះវិហារ ឧត្តរមានជ័យ និង ៤.០០០ (បួនពាន់)រៀល សំរាប់ប្រជាពលរដ្ឋ ដែលមានទីលំនៅក្រៅពីខេត្តខាងលើ ។

ក- ករណីអ្នកទទួលមរណភាព ទុកឱ្យហួសរយៈពេល ១៥ថ្ងៃ នៅក្នុងឆ្នាំ :

បើមានអ្នកស្លាប់ទុកឱ្យហួសរយៈពេល១៥ថ្ងៃ នៅក្នុងឆ្នាំ ពុំបានទៅរាយការណ៍ចុះសៀវភៅអត្រានុកូលដ្ឋាន មរណភាពទេ ក្រុមគ្រួសារនៃអ្នកស្លាប់ ត្រូវប្តឹងសុំសំបុត្រមរណភាពពីមេឃុំ ចៅសង្កាត់ នៃទីកន្លែងដែលកើតប្រាកដរបស់ អ្នកស្លាប់។

អ្នកប្តឹងសុំត្រូវមានលិខិតស្នាមមួយចំនួនដូចខាងក្រោម ÷

- ពាក្យប្តឹងសុំចុះសៀវភៅមរណភាពរបស់ក្រុមគ្រួសារ នៃអ្នកស្លាប់ចំនួន ០១ ច្បាប់ ដែលបិទតែមប្រើថ្លៃ ១.០០០ រៀល សំរាប់ប្រជាពលរដ្ឋដែលមានទីលំនៅ នៅខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ព្រះវិហារ ឧត្តរមានជ័យ និង បិទតែមប្រើថ្លៃ ៤.០០០ រៀល សំរាប់ប្រជាពលរដ្ឋដែលមានទីលំនៅក្រៅពីខេត្តខាងលើ ។ ចំពោះការបិទតែមប្រើតម្លៃ ១.០០០ រៀល និង ៤.០០០ រៀល លើពាក្យប្តឹងសុំ គឺជំនួសឱ្យការបង់ប្រាក់ផ្ទាល់ ។

- សៀវភៅគ្រួសារ ឬ សេចក្តីចម្លងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់អ្នកប្តឹងសុំចុះសៀវភៅមរណភាព ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមន្ទីរពេទ្យ បើស្លាប់ក្នុងមន្ទីរពេទ្យ ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយផ្នែកអនាម័យ បើស្លាប់ដោយរោគឆ្លង ឬ
- លិខិតជូនដំណឹងមរណភាពពីសមត្ថកិច្ចជំនាញ បើស្លាប់ដោយឃាតកម្ម ឬ ឧក្រិដ្ឋកម្ម ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមេភូមិ បើស្លាប់ក្នុងភូមិ ឬ
- លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវតាម ក្រសួង ស្ថាប័ន ឬ អង្គភាព បើស្លាប់នៅក្នុងស្ថាប័ន ឬ អង្គភាព ឬ
- សៀវភៅគ្រួសារដែលមានឈ្មោះអ្នកស្លាប់ (ប្រសិនបើមាន) ឬ
- សេចក្តីចម្លងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់អ្នកស្លាប់ (ប្រសិនបើមាន) ។

ខ- ករណីអ្នកទទួលមរណភាពទុកឱ្យហួសឆ្នាំ :

បើមានអ្នកស្លាប់ទុកអោយហួសឆ្នាំ ហើយពុំបានទៅរាយការណ៍ចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពទេ ក្រុមគ្រួសារនៃអ្នកស្លាប់ ត្រូវប្តឹងសុំសាលក្រមពីតុលាការខេត្ត ក្រុងសាមី រួចយកសាលក្រមនោះមកសុំមន្ត្រីអត្រានុ-កូលដ្ឋានឃុំ សង្កាត់ នៃអ្នកស្លាប់ ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព។

អ្នកប្តឹងសុំ ត្រូវមានលិខិតស្នាមមួយចំនួនដូចខាងក្រោម ÷

- សៀវភៅគ្រួសារ ឬ សេចក្តីចម្លងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់អ្នកប្តឹងសុំ
- សាលក្រមបញ្ជាក់ពីមរណភាពរបស់តុលាការខេត្ត ក្រុងសាមី
- សៀវភៅគ្រួសារដែលមានឈ្មោះអ្នកស្លាប់ (ប្រសិនបើមាន) ឬ
- សេចក្តីចម្លងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់អ្នកស្លាប់ (ប្រសិនបើមាន) ឬ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ របស់អ្នកប្តឹងសុំ (ប្រសិនបើមាន) ។

កំណត់ចំណាំ :

ដោយឡែកចំពោះអ្នកស្លាប់នៅចុងខែ ធ្នូ នៃឆ្នាំកំពុងអនុវត្ត ហើយរយៈពេល ១៥ថ្ងៃ អាចឆ្លងចូលដល់ឆ្នាំបន្ទាប់ ក្រុមគ្រួសារអាចមកប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនៅក្នុងឆ្នាំកំពុងអនុវត្ត ឬ នៅឆ្នាំបន្ទាប់បាន ។

ចំពោះអ្នកស្លាប់នៅចុងខែធ្នូនៃឆ្នាំកំពុងអនុវត្ត ហើយរយៈពេល ១៥ថ្ងៃ ឆ្លងចូលដល់ឆ្នាំបន្ទាប់ តែទុកឱ្យហួសរយៈពេលដែលបានកំណត់នេះអាចប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនៅឆ្នាំបន្ទាប់បាន ដោយត្រូវអនុវត្តទៅតាមបែបបទចំណុច "២" នៃចំណុចធំ " V " ស្តីពីករណីអ្នកទទួលមរណភាពទុកឱ្យហួសរយៈពេល ១៥ថ្ងៃ ។

VI- បែបបទ នីតិវិធី របៀបកត់ត្រាការងារអត្រានុកូលដ្ឋានតាមលក្ខណៈធម្មតា :

ការងារកត់ត្រាសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទ ការថែរក្សាសៀវភៅអត្រានុកូលដ្ឋាន ការចម្លងសំបុត្រអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋាន ស្មៀនឃុំ សង្កាត់ និង មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន ត្រូវអនុវត្តឱ្យបានត្រឹមត្រូវ ហ្មត់ចត់ ច្បាស់លាស់តាមបែបបទ នីតិវិធី របៀបកត់ត្រាការងារអត្រានុកូលដ្ឋាន ដែលបានកំណត់នៅក្នុងកម្រងឯកសារស្តីពីរបៀបកត់ត្រា ការងារអត្រានុកូលដ្ឋាន បោះពុម្ពនាខែ កក្កដា ឆ្នាំ ២០០៥ សម្រាប់ការងារអត្រានុកូលដ្ឋានដំណើរការតាមលក្ខណៈធម្មតា ។

រាល់បែបបទ នីតិវិធី របៀបកត់ត្រាការងារអត្រានុកូលដ្ឋាន សម្រាប់យុទ្ធនាការចុះសៀវភៅអត្រានុកូលដ្ឋានចល័ត ត្រូវបញ្ឈប់មិនឱ្យយកមកអនុវត្តទៀតឡើយ ។

VII- ចំណាំ និង ការទទួលខុសត្រូវចំពោះមុខច្បាប់ ស្តីពីការងារអត្រានុកូលដ្ឋាន :

- រាល់សំបុត្រអត្រានុកូលដ្ឋានថតចម្លង មិនមានតម្លៃជាផ្លូវការឡើយ ។ មន្ត្រីអត្រានុកូលដ្ឋាន អាជ្ញាធរស្រុក ខណ្ឌ ខេត្ត ក្រុង មិនត្រូវបញ្ជាក់លើសំបុត្រអត្រានុកូលដ្ឋានថតចម្លងឡើយ ។

- ហាមយកសំបុត្រអត្រានុកូលដ្ឋានរបស់ជនណាម្នាក់ទៅប្រើប្រាស់ធ្វើជាសំបុត្រអត្រានុកូលដ្ឋានផ្ទាល់ខ្លួន របស់ជនណាម្នាក់ទៀត។ សំបុត្រអត្រានុកូលដ្ឋានរបស់ជនណាមួយ ជាកម្មសិទ្ធិសម្រាប់តែជននោះប៉ុណ្ណោះ មិនអនុញ្ញាតឱ្យជនដទៃយកទៅប្រើប្រាស់ធ្វើជាសំបុត្រអត្រានុកូលដ្ឋានផ្ទាល់ខ្លួនឡើយ ។

- ហាមចុះសៀវភៅអត្រានុកូលដ្ឋានប្រភេទនីមួយៗ លើសពីមួយដងសម្រាប់មនុស្សតែម្នាក់ នៅច្រើនកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា ។

- សំបុត្រអត្រានុកូលដ្ឋាន និង សេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន ដែលមានកោស ឆូត លុប សរសេរជ្រៀតថែម មិនមានតម្លៃប្រើប្រាស់ជាផ្លូវការទេ ។

- ការចុះសៀវភៅអត្រានុកូលដ្ឋានតាមប្រភេទនីមួយៗ សាមីខ្លួន អ្នករាយការណ៍ សាក្សីត្រូវសម្តែងនូវការស្មោះត្រង់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ចំពោះការបញ្ជាក់អះអាងរបស់ខ្លួន អំពីហេតុការណ៍ដែលកើតមានឡើង ហើយដែលខ្លួនបានដឹងឮ ឬ ឃើញផ្ទាល់ ។

- ជនណារាយការណ៍មិនពិត អំពីអត្រានុកូលដ្ឋានចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ឬ យកអត្រានុកូលដ្ឋានរបស់អ្នកដទៃទៅប្រើប្រាស់ជារបស់ខ្លួន ឬ រាយការណ៍សុំចុះអត្រានុកូលដ្ឋានលើសពីមួយដង នៅកន្លែងដដែល ឬ កន្លែងផ្សេងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ ប្រើប្រាស់អត្រានុកូលដ្ឋានក្លែងបន្លំ ត្រូវពិន័យ និង ត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

- មន្ត្រីអត្រានុកូលដ្ឋាន ត្រូវស្មោះត្រង់ក្នុងការធ្វើអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋ ។ បើមន្ត្រីអត្រានុកូលដ្ឋានណា សមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋានឱ្យប្រជាពលរដ្ឋដែលមកសុំ ឬ បានទារប្រាក់លើសពីការកំណត់ពីប្រជាពលរដ្ឋ សម្រាប់ការងារអត្រានុកូលដ្ឋានត្រូវពិន័យ និង ត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

VIII- ការបង់ថ្លៃក្រដាស និង ថ្លៃតែមប្រើលើសំបុត្រអត្រានុកូលដ្ឋាន :

ការសុំសំបុត្រអត្រានុកូលដ្ឋាន កំណើត និង មរណភាព ច្បាប់ដើមមួយសន្លឹកក្នុងរយៈពេលកំណត់ មិនត្រូវឱ្យបង់ថ្លៃឡើយ ។

ថ្លៃក្រដាសអត្រានុកូលដ្ឋាន និង តែមប្រើត្រូវអនុវត្តតាមអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការកំណត់ថ្លៃជាវក្រដាសអត្រានុកូលដ្ឋាន និង ថ្លៃតែមប្រើសារពើពន្ធ ។

ដោយឡែកចំពោះពាក្យប្តឹងសុំសំបុត្រអត្រានុកូលដ្ឋាន កំណើត និង មរណភាព ហួសពេលកំណត់ ត្រូវបិទតែមប្រើចំនួន ១.០០០ រៀល ចំពោះប្រជាពលរដ្ឋដែលមានទីលំនៅនៅខេត្ត រតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ព្រះវិហារ និង ឧត្តរមានជ័យ និង ចំនួន ៤.០០០ រៀល សំរាប់ប្រជាពលរដ្ឋដែលមានទីលំនៅក្រៅពីខេត្តខាងលើ ។

ចំពោះការបិទតែមប្រើតម្លៃ ១.០០០ រៀល និង ៤.០០០ រៀល លើពាក្យប្តឹងសុំ គឺជំនួសឱ្យការបង់ប្រាក់ផ្ទាល់ ។

ថវិកាដែលបានមកពីការងារអត្រានុកូលដ្ឋាននៅឃុំ សង្កាត់ ត្រូវបង់ចូលថវិកាឃុំ សង្កាត់ ។

ថវិកាដែលបានមកពីការចម្លងអត្រានុកូលដ្ឋានគ្រប់ប្រភេទនៅសាលាស្រុក ខណ្ឌ ត្រូវបង់ចូលថវិកាខេត្ត ក្រុង ។

ទទួលបានសេចក្តីណែនាំនេះ សូមឯកឧត្តមអភិបាលគ្រប់ខេត្ត ក្រុង អភិបាលគ្រប់ស្រុក ខណ្ឌ និង ក្រុមប្រឹក្សាឃុំ សង្កាត់ ចាត់ចែងផ្សព្វផ្សាយ និង ចាត់វិធានការអនុវត្តឱ្យទទួលបានលទ្ធផលល្អប្រសើរ និង មានប្រសិទ្ធភាពខ្ពស់ ។

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង

ចម្លងជូន :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័ន

"ដើម្បីជូនជ្រាប"

-គ្រប់អង្គភាពចំណុះទីស្តីការក្រសួងមហាផ្ទៃ

-គ្រប់សាលាខេត្ត ក្រុង

"ដើម្បីអនុវត្ត"

-ឯកសារ កាលប្បវត្តិ

kinira 11.04.07

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង : ....

ស្រុក ខណ្ឌ : ....

ឃុំ សង្កាត់ : ....

ភូមិ : ....

លេខ : ....

លិខិតបញ្ជាក់ទទួលស្គាល់កំណើតទារក

យើង ....ជាមេភូមិ ....ឃុំ សង្កាត់ .... ស្រុក ខណ្ឌ .... ខេត្ត ក្រុង .... សូមបញ្ជាក់ថា (នាមត្រកូល និង នាមខ្លួនទារក) .... ភេទ .... កើតនៅថ្ងៃទី .... ខែ .... ឆ្នាំ .... នៅភូមិ .... ឃុំ សង្កាត់ .... ស្រុក ខណ្ឌ .... ខេត្ត ក្រុង .... ឪពុកឈ្មោះ .... កើតនៅថ្ងៃទី .... ខែ .... ឆ្នាំ .... និង ម្តាយឈ្មោះ .... កើតនៅថ្ងៃទី .... ខែ .... ឆ្នាំ.............. មានទីលំនៅបច្ចុប្បន្ននៅភូមិ .... ឃុំ សង្កាត់ .... ស្រុក ខណ្ឌ .... ខេត្ត ក្រុង .... ពិតជាបានកើតនៅផ្ទះប្រាកដមែន ដែលមានឆ្មបបង្កើតឈ្មោះ .... ភេទ .... ឆ្នាំកំណើត .... ទីលំនៅបច្ចុប្បន្ននៅភូមិ ....ឃុំ សង្កាត់ ....ស្រុក ខណ្ឌ ....ខេត្ត ក្រុង .... ។

ធ្វើនៅ .... ថ្ងៃទី .... ខែ .... ឆ្នាំ ....

មេភូមិ

ហត្ថលេខា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ពាក្យស្នើសុំសំបុត្រអត្រានុកូលដ្ឋាន(១) ....

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ .... សញ្ជាតិ ....ឆ្នាំកំណើត ....

មុខរបរបច្ចុប្បន្ន : ....

ទីលំនៅបច្ចុប្បន្ន : ផ្ទះលេខ..................... នៅភូមិ................. ឃុំ សង្កាត់ (២) ....

ស្រុក ខណ្ឌ(២) ....ខេត្ត ក្រុង(២) .... ។

<u>សូមគោរពជូន</u>

មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ (២) ....

<u>កម្មវត្ថុ</u> : សំណើសុំចុះសៀវភៅអត្រានុកូលដ្ឋាន..........................របស់ឈ្មោះ ....

<u>យោង</u> : - លិខិត(៣)..លេខ......... ចុះថ្ងៃទី ....ខែ........... ....

ឆ្នាំ....................របស់... ។

សេចក្តីដូចបានជំរាបជូនក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំបាទ-នាងខ្ញុំ សូមជំរាបជូន លោក /លោកស្រី មន្ត្រីអត្រានុកូលដ្ឋាន មេត្តាជ្រាបថា :ឈ្មោះ...................................ត្រូវជា...........................ពុំទាន់បាន ចុះសៀវភៅអត្រានុកូលដ្ឋាន..នៅឡើយ ។

អាស្រ័យហេតុនេះ សូម លោក /លោកស្រី មន្ត្រីអត្រានុកូលដ្ឋាន មេត្តាចុះសៀវភៅ អត្រានុកូលដ្ឋាន(១) ....តាមសំណើ ខ្ញុំបាទ/ នាងខ្ញុំដោយអនុគ្រោះ ។

ជូនភ្ជាប់មកជាមួយនូវ.. ចំនួន ០១ ច្បាប់ ។

ធ្វើនៅ.......................... ថ្ងៃទី .... ខែ .... ឆ្នាំ ....

ស្នាមមេដៃស្តាំអ្នកស្នើ

ឈ្មោះ ....

<u>សំគាល់</u> : (១) កំណើត មរណភាព

(២) គូសចោលនូវពាក្យដែលមិនប្រើ (៣) លិខិតពាក់ព័ន្ធសំរាប់បញ្ជាក់ជាភស្តុតាង

sour-form

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០៤១៤ ពណ.នគក

ភ្នំពេញថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ក្រូក**
CROC Co.,Ltd.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 9513/07P ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០៧
មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត
២- អភិបាលក្រុមហ៊ុន : លោក **KIM JUNG WOOK** ប្រធានក្រុមប្រឹក្សាភិបាល
លោក **សី ស៊ីវយ៉េង** អភិបាល
៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល
៤- ទីស្នាក់ការក្រុមហ៊ុន : ភូមិសាលាកន្សែង ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ។
៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញ គ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការដូលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការដូសដុលសំភារៈទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

គឹម_ស៊ីថៈ

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
